# កប្បកថា

## សំដែងអំពីកប្បចំរើន នឹង កប្បវិនាស

*មានភ្លើងឆេះកប្បជាដើម*



ឧបត្ថម្ភការសិក្សាធម្មវិន័យ

*ការផ្សាយរបស់បណ្ណាគារ ប៉ោ - ហ៊ាត លេខ ៩៧ វិថីហង្សវីរុស្ស៊ីយេ*

# កប្បកថា

## សម្ដែងអំពីកប្បចម្រើននិងកប្បវិនាស
## មានភ្លើងឆេះកប្បជាដើម

ព្រះបាឡាត់ឧត្តមលិខិត សុង-ស៊ីវ
សិទ្ធត្ថោ
ដកស្រង់ប្រែរៀបរៀង

បោះពុម្ពលើកទី១
ព.ស.២៤៩៥ គ.ស.១៩៥២
ការផ្សាយរបស់បណ្ណាគារ ថៅ-ហ៊ាត លេខ១៩៧ វិថីហង្សវិរស្ស៊ីយេ
ក្រុងភ្នំពេញ

# រតនប្រណាម

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

ខ្ញុំព្រះករុណាសូមនមស្ការ ចំពោះព្រះភគវន្តមុនី អរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ព្រមទាំងព្រះធម៌និងព្រះអរិយសង្ឃដោយគោរព។

## សាធរំ សាធរំ ហន្តុវិហាតា វិហាតា មយា

## វន្ទនា វន្ទនា មាន ភាជនេ រតនត្តយេ។

កិរិយាថ្វាយបង្គំឯណា ដែលខ្ញុំព្រះករុណា បានធ្វើឱ្យប្រកបដោយសេចក្ដីគោរពក្នុងប្រជុំបីនៃរតនៈ មានព្រះពុទ្ធជាដើម ដែលជាភាជន៍ គួរតែបុគ្គលថ្វាយបង្គំបូជាដោយទ្វារទាំងបីមានកាយទ្វារជាដើម កិរិយាថ្វាយបង្គំនោះឯង ជាអំពើដ៏វិសេស ព្រោះញុំាងសម្បត្តិជាលោកិយនិងលោកុត្តរឱ្យសម្រេចបាន សូមញុំាងសេចក្ដីក្រវល់ក្រវាយដែលប្រព្រឹត្តទៅក្នុងកាយនិងចិត្តនៃខ្ញុំព្រះករុណាឱ្យវិនាសបាត់បង់ទៅ។

ថ្ងៃទី១០ មិថុនា គ.ស.១៩៥២

ព្រះបាឡាត់ឧត្តមលិខិត សុង-ស៊ីវ

សិទ្ធត្ថោ

# អារម្ភកថា

ការរៀបរៀងសៀវភៅនេះ ខ្ញុំបានដកស្រង់សេចក្តីក្នុងគម្ពីរផ្សេងៗ មានគម្ពីរទីឃនិកាយនិងវិសុទ្ធិមគ្គជាដើម ដែលមាននិយាយអំពីកប្ប យកមកប្រែរៀបរៀងប្រកបឱ្យកើតជាសៀវភៅនេះឡើង បានសន្មតឱ្យឈ្មោះថា "កប្បកថា" ការសម្តែងអំពីកប្ប ដើម្បីជាគ្រឿងប្រដាប់សតិបញ្ញារបស់ពុទ្ធមាមកជនទូទៅនិងជាគ្រឿងពិចារណាក្នុងបញ្ហាជីវិតរបស់សត្តនិករនិងវត្ថុធាតុគ្រប់ប្រភេទ ឱ្យឃើញប្រចក្សថាមានខ្លឹមសារឬមិនមាន, ទៀងឬមិនទៀង។

សៀវភៅនេះ ខ្ញុំបានរៀបរៀងតាំងពីព.ស.២៤៩១ កាលដែលនៅជានិស្សិតសាលាបាលីជាន់ខ្ពស់នៅឡើយ ប៉ុន្តែមិនបានឡើងកាន់ពុម្ព, ដល់មកព.ស.២៤៩៥ នេះ ថៅកែ ប៉ោ-ហ៊ត បានមកអារាធនាឱ្យរៀបរៀងរឿងនេះដើម្បីបោះពុម្ពផ្សាយ ខ្ញុំក៏ជូនសៀវភៅនេះចំពោះថៅកែ ប៉ោ-ហ៊ន តែម្តង ដើម្បីឱ្យចាត់ការបោះពុម្ពផ្សាយតាមសេចក្តីត្រូវការ។

វត្តលង្កា, ថ្ងៃទី១០ មិថុនា គ.ស.១៩៥២

ព្រះបាឡាត់ឧត្តមលិខិត **សុង-ស៊ីវ**

**សិទ្ធត្ថោ**

គ្រូបង្រៀនបាលីនៅវត្តលង្កា

# បញ្ជីមាតិកាធម៌


មាតិកានុក្រម លេខទំព័រ

ឧបាយប្រចាំជីវិត........................................០៤

អំពីពាក្យថាកប្ប........................................០៦

ទ្វីប៤........................................០៩

ពុទ្ធក្សេត្រ៣យ៉ាង........................................១១

យោបល់ផ្សេងគ្នាក្នុងពុទ្ធក្សេត្រ........................................១៣

ឧបមាអំពីកប្ប........................................១៥

ការចែកកប្ប........................................១៧

កប្បវិនាសដោយភ្លើង........................................១៩

កប្បវិនាសដោយទឹកនិងខ្យល់........................................២១

កប្បចម្រើន........................................២៣

សត្វបរិភោគដីមានរស........................................២៦

រឿងព្រះបាទទល្ហនេមិ........................................៣១

ការកើតអកុសលកម្មបថក្នុងលោក........................................៣៥

ការកើតសត្ថន្តរកប្ប........................................៤០

ការកើតកុសលកម្មបថក្នុងលោក........................................៤០

# កប្បកថា

## ឧបាយប្រចាំជីវិត

ដើម្បីបន្ធូរបន្ថយចិត្តកុំឱ្យលិចលង់ទៅក្នុងអំពីទុច្ចរិតផ្សេងៗ គួរគិតពិចារណាដល់គ្រោះថ្នាក់ ការវិនាសអន្តរធានរបស់ពិភពលោក ដែលទុកជាផ្ទះសំបែងជាគូហា ឬជាអន្លង់របស់យើងគេ ដែលយើងគេត្រូវតែកើត ត្រូវតែនៅអាស្រ័យ គេរត់ចៀសចេញមិនរួច។ ធម្មតាអ្នកនៅក្នុងផ្ទះដែលចាក់សោជាប់មាំមួន ហើយប្រហែសធ្វេសមិននឹកនាដល់គ្រោះថ្នាក់គិតតែដេកសប្បាយក្នុងផ្ទះ បណ្ដោយសតិស្មារតីឱ្យវង្វេងភ្លេចបាត់កូនសោ ដល់វេលាភ្លើងឆេះផ្ទះ ស្រាប់តែភ័យញ័រចំប្រប់ស្លុតព្រលឹងរត់ស្រែកអន្ទះសាទទួលទុក្ខសោកយ៉ាងមហិមា ដរាបដល់ភ្លើងឆេះខ្លោចខ្លីប្រកាច់ស្លាប់ក្នុងគំនរភ្លើងនោះ។ មានឧបមាយ៉ាងណាមិញ ពួកសត្តនិករក្នុងលោក ដែលផោកផង់ស្ទុះស្ទុងគំនិតទៅក្នុងអំពើទុច្ចរិតផ្សេងៗ មិនបាននឹកដល់គ្រោះថ្នាក់ប្រចាំជីវិត គិតតែសប្បាយហួសហេតុ ខុសលំនាំអ្នកប្រាជ្ញក៏ដូច្នោះដែរ។

ធម្មតាអ្នកប្រាជ្ញ អ្នកមានគំនិតប្រព្រឹត្តទៅមុនជីវិត តែងរិះរកឧបាយដើម្បីចៀសវាងគ្រោះថ្នាក់ប្រចាំជីវិតទុកមុនជាដរាប មិនបណ្ដោយឱ្យជីវិតលឿនទៅប៉ះទង្គិកពានពារលើគំនរគ្រោះថ្នាក់ឡើយ។ ឧបាយដែលនឹងចៀសវាងគ្រោះថ្នាក់នោះមានតែមួយទេ គឺសុចរិតធម៌, សុចរិតកាយ គឺមិនបៀតបៀនជីវិតរបស់ខ្លួននិងសត្វដទៃ មិនលួចប្លន់បុត្រភរិយាស្វាមីនិងទ្រព្យសម្បត្តិរបស់ជនដទៃនិងមិនផឹកសុរាជាដើម, សុចរិតវាចា គឺមិននិយាយកុហកភូតភរញុះញង់ បំបែកបំបាក់ចាក់ចុចធ្វើឱ្យអ្នកដទៃវិនាសជាដើម, សុចរិតចិត្ត គឺមិនគុំគួនព្យាបាទអ្នកដទៃនិងមិនរបឹងរឹងរូសចចេសជំទាស់នឹង

សភាវៈពិត ចេះជឿកម្មនិងផលរបស់កម្មជាដើម។ បើបុគ្គលណាមានសុចរិតធម៌នេះហើយ បុគ្គលនោះជាបណ្ឌិតមានគំនិតល្អ មិនបណ្ដោយឱ្យជីវិតលឿនទៅប៉ះទង្គិចពានពារលើគំនរគ្រោះថ្នាក់ឡើយ។

ឃ.គ្រោះថ្នាក់នោះ ដោយសង្ខេបមានពីរយ៉ាងគឺ:

១–គ្រោះថ្នាក់មិនប្រចាំកាល

២–គ្រោះថ្នាក់ប្រចាំកាល។

១)–គ្រោះថ្នាក់មិនប្រចាំកាលនោះ បានដល់គ្រោះថ្នាក់របស់សត្វដូចជាក្នុងបច្ចុប្បន្នកាលនេះ។ ក្នុងប្រទេសមួយ តំបន់មួយជាមួយគ្នា សត្វខ្លះមានគ្រោះថ្នាក់ ខ្លះបានសុខចម្រើន ជួនកាលថ្ងៃខែឆ្នាំនេះ សត្វនោះមានគ្រោះថ្នាក់, ថ្ងៃខែឆ្នាំនោះ សត្វនេះមានគ្រោះថ្នាក់មិនកំណត់កាលកំណត់សត្វ ដូច្នេះហៅថាគ្រោះថ្នាក់មិនប្រចាំកាល។

២)–គ្រោះថ្នាក់ប្រចាំកាលនោះ បានដល់គ្រោះថ្នាក់ប្រចាំអាយុផែនដីយូរអង្វែងណាស់ទើបមានម្ដង។ គ្រោះថ្នាក់នេះធំក្រៃលែងធំ ដែលពាក្យចាស់ទុំតែងនិយាយថាកើតអន្តរធានភ្លើងឆេះទឹកភ្លើងឆេះដី ភ្លើងប្រល័យកប្ប។ ក្នុងពេលភ្លើងប្រល័យកប្បនោះ ពួកសត្តនិករដែលនៅលើផែនដីទាំងប៉ុន្មាននិងនៅក្នុងស្ថានសួគ៌ទៅទល់ត្រឹមសុទ្ធាវាសព្រហ្ម ត្រូវទទួលគ្រោះថ្នាក់ទាំងអស់ចំពោះសត្វណាដែលធ្វេសប្រហែស មិនអើពើនឹងសុចរិតធម៌ ព្រោះក្នុងពេលនោះ ធម្មតាកុសលាកុសលកម្មនិងសង្ខារត្រូវបែងចែកសត្វ គឺសត្វណាដែលល្មោភប្រព្រឹត្តអំពើទុច្ចរិត សត្វនោះត្រូវទៅជួបជុំកើតក្នុងពេលនោះទីនោះ សត្វណាដែលបានប្រព្រឹត្តសុចរិតធម៌ហ្មត់ចត់ល្អ សត្វនោះត្រូវទៅកើតនៅកន្លែងសុខក្សេមក្សាន្ត មានទៅកើតក្នុងសុទ្ធាវាសព្រហ្មជាដើម មិនបាននៅប្រឡូកប្រឡំជាមួយនឹងពួកអ្នកប្រព្រឹត្តទុច្ចរិតនោះឡើយ, ដូច្នេះហៅថាគ្រោះថ្នាក់

ប្រចាំកាល។ គ្រោះថ្នាក់នេះកាន់តែលឿនជិតមកដល់ហើយ ព្រោះតែដីដែលយើងគេនៅអាស្រ័យសព្វថ្ងៃនេះ មានឈ្មោះតាមអាយុហៅថា ភទ្ទកប្ប មានព្រះពុទ្ធ៥ព្រះអង្គត្រូវឧប្បត្តិកើតឡើងក្នុងរយៈកាលអាយុផែនដីនេះ, ឥឡូវបរិនិព្វានផុត៤ព្រះអង្គទៅហើយ គឺព្រះពុទ្ធកកុសន្ធោ, កោនាគមនោ, កស្សបោ, គោតមោ, នៅសល់តែព្រះអរិយមេត្តេយ្យមួយអង្គទៀតទេត្រូវភ្លើងប្រល័យកប្បហើយ។

ពាក្យថាកប្បនិងរឿងភ្លើងប្រល័យកប្បនោះ នឹងមានសម្ដែងតទៅនេះ។

# អំពីពាក្យថាកប្ប

កាលដែលតាំងនៅយូរអង្វែងហៅថាកប្ប ជាឈ្មោះអាយុផែនដីឬជាឈ្មោះអាយុឱកាសលោក។ ដែលហៅថាឱកាសលោកនោះ ក្នុងគម្ពីរវិសុទ្ធិមគ្គប្រាប់ថាៈ បានដល់ទីលំនៅរបស់សត្តនិករ ដែលមានសេចក្ដីវិនាសជាធម្មតា។ ក្នុងឱកាសលោកនោះ មានចក្កវាឡ[១]ជាច្រើន ចក្កវាឡយើងនេះមានបណ្ដោយនិងទទឹងប្រវែងមួយលានពីរសែនបីពាន់បួនរយហាសិបយោជន៍[២] (១.២០៣.៤៥០យោជន៍), បរិមណ្ឌលសំណុំមូលជុំវិញបីលានប្រាំមួយសែនមួយម៉ឺនបីរយហាសិបយោជន៍ (៣.៦១០.៣៥០យោជន៍), កម្រាស់ផែនដីក្នុងចក្កវាឡនេះចំនួនពីរសែនបួនម៉ឺនយោជន៍ (២៤០.០០០យោជន៍), ទឹកទ្រផែនដីកម្រាស់បួនសែនប្រាំបីម៉ឺនយោជន៍ (៤៨០.០០០យោជន៍) មានភ្នំធំឈ្មោះសិនេរុ ចាក់ឫសលិចទៅក្នុងសមុទ្រ ជម្រៅប្រាំបីម៉ឺនបួនពាន់យោជន៍ (៨៤.០០០យោជន៍), ខ្ពស់ឡើងលើប្រាំបីម៉ឺនបួនពាន់យោជន៍ដូចគ្នា, បន្ទាប់អំពីភ្នំសិនេរុនោះមក មានភ្នំសត្តបរិភណ្ឌ៧ជាន់ទៀតគឺៈ

| | | |
|---|---|---|
| ១-យុគន្ធរ | មានកម្ពស់ | ៤២.០០០យោជន៍ |
| ២-ឥសិន្ធរ | មានកម្ពស់ | ២១.០០០យោជន៍ |

៣-ករវីក មានកម្ពស់ ១០.៥០០យោជន៍

៤-សុទស្សន មានកម្ពស់ ៥.២៥០យោជន៍

៥-នេមិន្ធរ មានកម្ពស់ ២.៦២៥យោជន៍

៦-វិនតក មានកម្ពស់ ១.៣១២យោជន៍

៧-អស្សកណ្ណ មានកម្ពស់ ៦៥៦យោជន៍ពាក់កណ្ដាលកន្លះ។

ភ្នំទាំង៧នេះសុទ្ធតែជាភ្នំទិព្វវិចិត្រដោយរតនវត្ថុផ្សេងៗ មានមាសជាដើម, មានឫសលិចចុះទៅក្រោមពាក់កណ្ដាល ស្មើនឹងកម្ពស់ឡើងលើព័ន្ធព័ទ្ធជុំវិញភ្នំសិនេរុ ចម្ងាយពីភ្នំមួយទៅភ្នំមួយ ប្រវែងស្មើនឹងកម្ពស់ភ្នំនោះៗ ក្នុងចន្លោះទាំង៧នោះសុទ្ធតែសមុទ្រទឹកគ្មានសរសៃ ហៅថាសមុទ្រសីទន្តរ។ ភ្នំទាំង៧នេះជាទីលំនៅនៃស្ដេចចតុលោកបាលទាំង៤គឺៈ ព្រះបាទធតរដ្ឋ១, វិរូបក្ខ១, វិរុឡ្ហកៈ១, កុវេរៈ១ និងជាទីនៅជាទីទៅមកនៃទេវតានិងយក្សទាំងឡាយ, មិនមែនជាវិស័យរបស់មនុស្សលោកទៅដល់មើលឃើញពិតបានប្រមាណត្រូវទេ មានតែព្រះសម្ពុទ្ធនិងព្រះអរហន្តទាំងឡាយទើបទៅដល់មើលឃើញ ដឹងស្គាល់ដោយសព្វគ្រប់បាន។ ភ្នំធំឈ្មោះសិនេរុនោះមានភ្នំ៣ទល់ពីក្រោម ហៅថាភ្នំត្រៃកូដ, ខាងលើកំពូលភ្នំសិនេរុនោះ ជាភូមិភាគរបស់សក្កទេវរាជ ហៅថាស្ថានតាវត្តិង្ស ខាងលើតទៅទៀត គឺស្ថានយាមា, តុសិតា, និម្មានរតី, បរនិម្មិតវសវត្តី។ ស្ថានទាំងនេះជាទីនៅអាស្រ័យរបស់ពពួកទេវតាទាំងអស់ មិនមែនជាទីនៅអាស្រ័យរបស់មនុស្សឡើយ។ ខាងលើតពីស្ថានទេវតាទៅទៀត ជាភូមិភាគរបស់ពួកព្រហ្មមានរូបនិងព្រហ្មគ្មានរូប។

## ព្រហ្មមានរូបមាន១៦ស្ថានគឺ

១-បរិសជ្ជា ៩-សុភកិណ្ហា

២-បុរោហិតា ១០-វេហប្ផលា

៣-មហាព្រហ្មា ១១-អញ្ញិសត្តា

៤-បរិត្តាភា ១២-អវិហា

៥-អប្បមាណាភា ១៣-អតប្បា

៦-អាភស្សរា ១៤-សុទស្សា

៧-បរិត្តសុភា ១៥-សុទស្សី

៨-អប្បមាណសុភា ១៦-អកនិដ្ឋា។

ព្រហ្មគ្មានរូបមាន៤ស្ថានគឺ

១-អាកាសានញ្ចាយតនៈ

២-វិញ្ញាណញ្ចាយតនៈ

៣-អាកិញ្ចញ្ញាយតនៈ

៤-នេវសញ្ញានាសញ្ញាយតនៈ។

ស្ថាននេវសញ្ញានាសញ្ញាយតនៈនេះ ជាស្ថានខាងលើបំផុតរបស់ភព របស់ឱកាសលោក។ ចម្ងាយពីទីបំផុតភពមកស្ថានមនុស្សលោកនេះ ឆ្ងាយក្រៃលែងឆ្ងាយនឹងកំណត់រាប់ជាប៉ុណ្ណេះប៉ុណ្ណោះយោជន៍មិនបាន។ ក្នុងគម្ពីរលោកទីបកៈ មានសម្តែងប្រៀបធៀបថាៈ

**សព្វភវគ្គេ ឋត្វាន កូដាគារសមាសិលា ចាតិតា តីហិ វស្សេហិ ទ្វិមាសេហិ ច អដ្ឋហិ រត្តិន្ទិវេហិ...** ដូច្នេះជាដើម។ សេចក្តីថា ទេវតាមានឫទ្ធិច្រើនស្ថិតនៅក្នុងទីបំផុតភព ហើយទម្លាក់នូវដុំថ្មធំប៉ុនផ្ទះ ពីកំពូលឱ្យធ្លាក់ចុះមកស្ថានមនុស្សលោក ធ្លាក់មកយូរអង្វែងណាស់ចំនួន៣ឆ្នាំ២ខែ៨ថ្ងៃនិង១៤នាទី ទើបដល់មកស្ថាន

មនុស្ស ដុំថ្មនោះគ្រាន់តែសឹកដោយខ្យល់ដាច់អស់នៅសល់ប៉ុនផ្លែក្រូចសើចប៉ុណ្ណោះ។

បន្ទាប់អំពីនេះ នឹងសម្តែងរៀបរាប់តាមគម្ពីរវិសុទ្ធិមគ្គជាដើមតទៅទៀត។ តាមតំណាលថា ភ្នំសិនេរុស្ថិតនៅកណ្តាលចក្កវាឡ, ភ្នំសត្តបរិភណ្ឌព័ទ្ធជុំវិញភ្នំសិនេរុ, ផ្ទៃខាងក្រៅភ្នំសត្តបរិភណ្ឌនោះសុទ្ធតែទឹកទាំងអស់ មានទ្វីប៤ស្ថិតនៅក្នុងទិសទាំង៤ ឆ្ងាយដាច់ស្រយាលពីភ្នំសត្តបរិភណ្ឌ។

## ទ្វីប៤នោះគឺ

១–ជម្ពូទ្វីប ស្ថិតនៅទិសខាងត្បូងភ្នំសិនេរុ មានដើមព្រីងប្រចាំទ្វីប មនុស្សក្នុងទ្វីបនោះរកស៊ីចិញ្ចឹមជីវិតដោយកសិកម្មនិងពាណិជ្ជកម្មជាដើម, ស្ត្រីមានគភ៌៩ខែឬ១០ខែទើបប្រសូតបុត្តធីតា។

២–ឧត្តរកុរុទ្វីប ស្ថិតនៅទិសខាងជើងភ្នំសិនេរុ មានដើមកប្បព្រឹក្សប្រចាំទ្វីប, មនុស្សក្នុងទ្វីបនោះមិនរវល់កង្វល់ដោយកសិកម្ម ពាណិជ្ជកម្មឡើយ ចង់បានអ្វី ចង់បរិភោគចំណីអាហារបែបណា គ្រាន់តែដើរទៅដល់ដើមកប្បព្រឹក្សបានដូចប្រាថ្នា, ស្ត្រីមានគភ៌៧ថ្ងៃប្រសូតបុត្តធីតា ប្រសូតបាន៧ថ្ងៃចេះដើរចេះរត់។

៣–អមរគោយានីទ្វីប ស្ថិតនៅទិសខាងលិចភ្នំសិនេរុ មានដើមក្ទម្ពប្រចាំទ្វីប, មនុស្សក្នុងទ្វីបនោះមិនកង្វល់ដោយកសិកម្ម ពាណិជ្ជកម្មឡើយ ព្រោះមានដួងកែវឱ្យសម្រេចសេចក្តីប្រាថ្នាបានគ្រប់យ៉ាង។

៤–បុព្វវិទេហទ្វីប ស្ថិតនៅទិសខាងកើតភ្នំសិនេរុ មានដើមច្រេសប្រចាំទ្វីប, មនុស្សក្នុងទ្វីបនោះមិនពិបាកនឿយហត់ដោយកសិកម្ម ពាណិជ្ជកម្មឡើយ ព្រោះមានប្រាសាទ១វិចិត្ររចនាដោយកែវ៧ប្រការកម្ពស់១៥យោជន៍ ឱ្យសម្រេចសេចក្តីត្រូវការរបស់មនុស្សបានគ្រប់យ៉ាង។

បណ្ដាទ្វីបទាំង៤នោះ ព្រះពុទ្ធគ្រប់ព្រះអង្គមិនដែលឧប្បត្តិកើតក្នុងទ្វីបទាំងបីទេ ទ្រង់ឧប្បត្តិកើតតែក្នុងជម្ពូទ្វីបមួយប៉ុណ្ណោះ ព្រោះទ្វីបទាំងបីជាទ្វីបសម្រាប់សត្វសោយផលរបស់សុចរិតធម៌ មិនមែនជាទ្វីបសម្រាប់សាងសុចរិតធម៌ដូចជម្ពូទ្វីបឡើយ។

ក្នុងជម្ពូទ្វីបមានភ្នំហិមវន្ត កម្ពស់ប្រាំរយយោជន៍ (៥០០យោជន៍) បណ្ដោយនិងទទឹងប្រវែងបីពាន់យោជន៍ (៣.០០០យោជន៍) មានកំពូលប្រាំបីម៉ឺនបួនពាន់យោជន៍ (៨៤.០០០យោជន៍)។

## ទំហំដើមឈើប្រចាំទ្វីបទាំង៤គឺ

ជម្ពូព្រឹក្ស ដើមព្រីងក្នុងជម្ពូទ្វីប១, កប្បព្រឹក្ស ដើមកប្បក្នុងឧត្តរកុរុទ្វីប១, កទម្ពព្រឹក្ស ដើមក្ទម្ពក្នុងអមរគោយានីទ្វីប, សិរីសព្រឹក្ស ដើមច្រេសក្នុងបុព្វវិទេហទ្វីប១និងបារិច្ឆត្តព្រឹក្ស ដើមរលួសផ្កុងក្នុងស្ថានតាវត្តិង្ស១, បាដលីព្រឹក្ស ដើមជ្រនៀងរបស់ពួកអសុរ១, សិម្ពលីព្រឹក្ស ដើមរការបស់ពួកគ្រុឌ១ ឈើទាំងអស់នេះសុទ្ធតែជាស្ដេចនៃរុក្ខជាតិ មានអាយុវែងតាំងនៅអស់១កប្ប មានទំហំនិងកម្ពស់ជាដើមប៉ុនគ្នាទាំងអស់គឺៈ មានសំណុំជុំវិញដើមចំនួនដប់ប្រាំយោជន៍ (១៥យោជន៍), បណ្ដោយដើមនិងបណ្ដោយមែក ដែលបែកទៅជុំវិញដើមម្ខាងនិងកម្ពស់មែកទៅខាងលើចំនួនមួយរយយោជន៍ (១០០យោជន៍)។

## ទំហំទ្វីបទាំង៤គឺ

ជម្ពូទ្វីបនិងស្ថានតាវត្តិង្ស, ស្ថានអសុរ, ស្ថាននរកអវិចី មានទំហំមួយម៉ឺនយោជន៍ដូចគ្នា (១០.០០០យោជន៍), អមរគោយានីទ្វីបនិងបុព្វវិទេហទ្វីប មានទំហំពីរពាន់យោជន៍ (២.០០០យោជន៍), ឧត្តរកុរុទ្វីប មានទំហំប្រាំបីពាន់យោជន៍ (៨.០០០យោជន៍)។ ទ្វីបទាំង៤នេះ ទ្វីបនីមួយៗមានទ្វីបតូចៗប្រាំរយៗជាបរិវារ រួមនៅក្នុងចក្កវាឡមួយ ជុំវិញ ចក្កវាឡ

មានភ្នំធំវែងព័ទ្ធជុំវិញ ភ្នំនោះចាក់ឫសចុះទៅក្នុងមហាសមុទ្រជម្រៅប្រាំបីម៉ឺនពីរពាន់យោជន៍ (៨២.០០០យោជន៍) ដុះខ្ពស់ឡើងលើមានកម្ពស់ប្រាំបីម៉ឺនពីរពាន់យោជន៍ដែរ។

## បញ្ជាក់សេចក្តី

ពាក្យថាលោកធាតុនិងចក្កវាឡ ជាពាក្យមួយ គ្រាន់តែផ្សេងគ្នាដោយសេចក្តីប៉ុណ្ណោះទេ។ ក្នុងលោកធាតុមួយឬចក្កវាឡមួយមានទ្វីបធំ៤ទ្វីបតូច១៥រយ, មានភ្នំសិនេរុ, ភ្នំសត្តបរិភណ្ឌ, ស្ថានសួគ៌៦ជាន់, ស្ថានព្រហ្ម, ស្ថានមនុស្សនិងស្ថាននរកជាដើម ហើយមានព្រះអាទិត្យ ព្រះចន្ទ។ ព្រះអាទិត្យនោះមានទំហំ៥០យោជន៍ ព្រះចន្ទមានទំហំ៤៩យោជន៍ ជាវិមានប្រាសាទរបស់សុរិយទេវបុត្រនិងចន្ទទេវបុត្រ, សង្ខារលោកតាក់តែងឡើងសម្រាប់បំភ្លឺលោក មានប្រក្រតីដើរប្រទក្សិណភ្នំសិនេរុជានិច្ច, ព្រះអាទិត្យក្នុងមួយយប់មួយថ្ងៃដើរបានមួយជុំភ្នំសិនេរុ, ព្រះចន្ទដើរមួយខែទើបបានមួយជុំភ្នំសិនេរុ។ រួបរួមសម្ភារៈទាំងអស់ដូចរៀបរាប់មកនេះហៅថា លោកធាតុមួយឬចក្រវាឡមួយ។

លោកធាតុឬចក្កវាឡនោះមានច្រើនជាអនេក មិនមែនមានតែមួយទេ រួមលោកធាតុឬចក្កវាឡដែលមានទាំងប៉ុន្មាន ហៅថា ឱកាសលោក។ ឱកាសលោកនោះបែងចែកទៅតាមខេត្តរបស់ព្រះពុទ្ធទៅទៀតគឺៈ

## ពុទ្ធក្ខេត្តមាន៣យ៉ាង

១–ជាតិក្ខេត្ត មានលោកធាតុឬចក្កវាឡចំនួនមួយម៉ឺន (១០.០០០លោកធាតុ) ក្នុងពេលដែលព្រះសម្ពុទ្ធចុះចាប់បដិសន្ធិនិងប្រសូតជាដើម លោកធាតុឬចក្កវាឡទាំងមួយម៉ឺននោះ កម្រើករំពើកញាប់ញ័រទាំងអស់ ហាក់ដូចជាគេចាប់ញាក់ឬចាប់អង្រួនដោយអំណាចបុណ្យរបស់ព្រះអង្គ។

២–អាណាខេត្ត មានលោកធាតុឬចក្កវាឡចំនួនមួយសែនកោដិ (១០០.០០០

កោដិលោកធាតុ) ក្នុងពេលដែលព្រះសម្ពុទ្ធសម្ដែងនូវរតនបរិត្ត, ខន្ធបរិត្ត, ធជគ្គបរិត្ត, អាដានាដិយបរិត្តនិងមោរបរិត្ត លោកធាតុឬចក្កវាឡទាំងមួយសែនកោដិនោះ កម្រើករំពើកញាប់ញ័រទាំងអស់ ហាក់ដូចជាគេចាប់ញាក់ឬចាប់អង្រួន ដោយអំណាចរបស់ព្រះបរិត្តដែលព្រះអង្គសម្ដែង។

៣–វិសយក្ខេត្ត មានលោកធាតុឬចក្កវាឡជាអនន្តរាប់មិនបានប្រមាណមិនត្រូវ, អំណាចប្រាជ្ញាញាណរបស់ព្រះសម្ពុទ្ធជ្រៅឆ្ងាយទូលាយជាអនន្ត ផ្សាយទៅក្នុងឱកាសលោកដែលរកទីបំផុតមិនឃើញបានតាមពុទ្ធបំណង បើព្រះអង្គចង់ជ្រាបនូវហេតុជាអនន្តបែបណា ទ្រង់ជ្រាបបានបែបនោះឥតមានទើសទាក់។

ពុទ្ធក្ខេត្តទាំងបីនោះ លើកលែងវិសយក្ខេត្តមួយចេញ ព្រោះជាធម្មតាវិស័យប្រាជ្ញាញាណរបស់ព្រះពុទ្ធគ្រប់ព្រះអង្គ។ ចំណែកខាងជាតិក្ខេត្តនិងអាណាខេត្ត ដែលមានលោកធាតុឬចក្កវាឡមួយសែនកោដិនោះ ជាខេត្តរបស់ព្រះសម្ពុទ្ធមួយអង្គៗ។ លោកធាតុឬចក្កវាឡទាំងមួយសែនកោដិនោះ សង្ខារលោកតាក់តែងឡើងក្នុងពេលជាមួយគ្នា មានអាយុស្ថិតនៅប្រហែលគ្នា វិនាសទៅវិញក៏តំណាលគ្នា ដូចមានសម្ដែងក្នុងគម្ពីរវិសុទ្ធិមគ្គ ត្រង់អភិញ្ញានិទ្ទេសថាៈ

ឯវមេតេសុ តីសុ ពុទ្ធក្ខេត្តេសុ ឯកំ អាណាខេត្តំ វិនស្សតិ។ តស្មឹ បន វិនស្សន្តេ ជាតិក្ខេត្តម្បិ វិនដ្ឋមេវ ហោតិ។ វិនស្សន្តញ្ច ឯកតោវ វិនស្សន្តិ។ សណ្ឋហន្តម្បិ ឯកតោវ សណ្ឋហតិ។ តស្សេវំ វិនាសោ ច សណ្ឋហនញ្ច វេទិតព្វំ។

សេចក្ដីថាៈ បណ្ដាពុទ្ធក្ខេត្តទាំងបីនោះ អាណាខេត្តមួយត្រូវវិនាស កាលបើអាណាខេត្តវិនាសហើយ ចំណែកខាងជាតិក្ខេត្ត ក៏ត្រូវវិនាសដូចគ្នាដែរ។ ជាតិក្ខេត្ត

កាលវិនាសក៏វិនាសក្នុងពេលជាមួយគ្នានឹងអាណាខេត្ត, កាលតាំងនៅក៏តាំងនៅក្នុងពេលជាមួយគ្នានឹងអាណាខេត្ត។ ការវិនាសក្តី តាំងនៅក្តីនៃជាតិក្ខេត្តនិងអាណាខេត្តនោះ បណ្ឌិតត្រូវជ្រាបយ៉ាងនេះចុះ។

ន័យត្រង់ពុទ្ធក្ខេត្តនេះ ច្រើនមានយោបល់យល់ផ្សេងៗគ្នា ខ្លះយល់ថា ក្នុងឱកាសលោកទាំងមូល ដែលមានមេឃអាកាសធំទូលាយល្ហល្ហេវនេះ មានលោកធាតុឬចក្កវាឡត្រឹមតែមួយសែនកោដិប៉ុណ្ណោះ យូរៗទើបមានព្រះពុទ្ធត្រាស់មួយអង្គ មិនមានជានិច្ចកាលរាល់ថ្ងៃរាល់ខែរាល់ឆ្នាំទេ ព្រោះមិនមានលោកធាតុឬចក្កវាឡដោយឡែកក្រៅពីមួយសែនកោដិនោះទៀត។

ខ្លះទៀតយល់ថា ក្នុងឱកាសលោកទាំងមូល ដែលមានមេឃអាកាសធំទូលាយល្ហល្ហេវនេះ មិនមែនមានលោកធាតុឬចក្កវាឡត្រឹមតែមួយសែនកោដិប៉ុណ្ណោះទេ គឺមានមួយសែនកោដិៗជាអនន្តរាប់មិនអស់ មានព្រះពុទ្ធត្រាស់រាល់ៗថ្ងៃគ្មានចន្លោះ គឺបើលោកធាតុមួយសែនកោដិនេះ ព្រះពុទ្ធបរិនិព្វានទៅហើយ លោកធាតុមួយសែនកោដិនោះ មានព្រះពុទ្ធកំពុងត្រាស់ដឹង, លោកធាតុមួយសែនកោដិឯណោះ មានព្រះពុទ្ធកំពុងចុះចាប់បដិសន្ធិ លោកធាតុមួយសែនកោដិឯណោះ មានព្រះពុទ្ធកំពុងចេញបព្វជ្ជាឬមានលោកធាតុមួយសែនកោដិៗជាច្រើន ដែលមានព្រះពុទ្ធកំពុងចុះចាប់បដិសន្ធិ, កំពុងតែប្រសូត, កំពុងតែបានត្រាស់ជាដើមឬក៏មានលោកធាតុមួយសែនកោដិជាច្រើនកំពុងតែវិនាស, មានលោកធាតុមួយសែនកោដិជាច្រើន ដែលកំពុងតែចម្រើន។

ការយល់ទាំងពីរស្ថាននេះ អ្នករៀបរៀងមិនបាច់វិនិច្ឆ័យថា ខាងណាខុសខាងណាត្រូវទេ គ្រាន់តែទាញហេតុផលមកបង្ហាញជាគ្រោងគំនិតទុកជាបានការ ស្រេច

លើពុទ្ធបរិស័ទដែលបានមើលសៀវភៅនេះវិនិច្ឆ័យចុះ បើឃើញថាខាងណាសមហេតុសមផលជាង ខាងនោះហើយត្រូវពិតប្រាកដ។

## គ្រោងគំនិត

១–ពុទ្ធក្ខេត្តមានបីគឺ ជាតិក្ខេត្ត, អាណាខេត្ត, វិសយក្ខេត្ត។ ខេត្ត ជាមគធភាសា ប្រែថា ស្រែ, តំបន់, នាទី,... គឺភាគផែនដីឬភាគផែនលោក ដែលគេសន្មតបែងចែកជាអន្លើៗ មានខ័ណ្ឌដោយរដ្ឋសភាបញ្ញត្តិឬដោយលោកប្បញ្ញត្តិជាសង្កាត់ៗកុំឱ្យច្រឡំគ្នា ព្រោះមានច្រើនមិនមែនមានតែមួយ។

២–ពុទ្ធក្ខេត្តទី១ គឺជាតិក្ខេត្ត មានកំណត់ត្រឹមតែមួយម៉ឺនលោកធាតុ, ព្រះពុទ្ធទ្រង់បដិសន្ធិជាដើម ចំពោះលោកធាតុណាមួយ ក្នុងក្រុមលោកធាតុមួយម៉ឺននោះ កម្រើករំពើកញាប់ញ័របានតែមួយម៉ឺនលោកធាតុប៉ុណ្ណោះ មិនបានកម្រើករំពើកញាប់ញ័រដល់លោកធាតុដទៃឡើយ។ ពុទ្ធក្ខេត្តទី២គឺ អាណាខេត្ត មានកំណត់ត្រឹមតែមួយសែនកោដិលោកធាតុ, ព្រះពុទ្ធទ្រង់សម្តែងនូវរតនបរិត្តនិងខន្ធបរិត្តជាដើម ក្នុងលោកធាតុណាមួយ ក្នុងក្រុមមួយសែនកោដិលោកធាតុនោះ កម្រើករំពើកញាប់ញ័របានតែមួយសែនកោដិលោកធាតុប៉ុណ្ណោះ មិនកម្រើករំពើកញាប់ញ័រដល់លោកធាតុដទៃឡើយ។ ហេតុដូចម្តេចបានជាពុទ្ធក្ខេត្តទី២ គឺអាណាខេត្ត មានកំណត់នាទីមួយសែនកោដិលោកធាតុដូច្នេះ? មានលោកធាតុលើសពីមួយសែនកោដិទៅទៀតឬ? ឬក៏គ្មានទេ? បើគ្មានហេតុអ្វីក៏ចាំមានកំណត់ មានខេត្ត មិនថាទាំងអស់តែម្តងទៅ? ព្រោះអាណាខេត្តនេះនិយាយចំពោះលោកធាតុក្នុងបច្ចុប្បន្នកាល មិនមែននិយាយចំពោះលោកធាតុ ដែលកន្លងផុតទៅហើយនោះទេ។

៣-ឱកាសលោក មេឃអាកាសនោះធំទូលាយជាអនន្តល្ហល្ហេវរកទីបំផុតដើម

មេឃមិនឃើញ សូម្បីពុទ្ធញាណក៏រាវរកមិនឃើញដែរ។ បើធំទូលាយយ៉ាងនេះ លោកធាតុមួយសែនកោដិៗ ជាអនន្តក៏មិនចង្អៀតមេឃអាកាសឡើយ ទាំងបីខនេះ ជាគ្រោងគំនិត សូមវិនិច្ឆ័យតាមន័យនេះចុះ។

ដែលរៀបរាប់មកនេះបែកមកអំពីពាក្យថាកប្ប ព្រោះពាក្យថាកប្បនេះ ជាឈ្មោះអាយុរបស់ផែនដី របស់ឱកាសលោកឬជាឈ្មោះអាយុរបស់លោកធាតុឬចក្ក-វាឡ។ លោកធាតុឬចក្កវាឡទាំងមួយសែនកោដិដែលជាខេត្តរបស់ព្រះពុទ្ធមួយអង្គៗនោះ សង្ខារលោកតាក់តែងសាងឡើងក្នុងពេលជាមួយគ្នា វិនាសទៅវិញក្នុងពេលជាមួយគ្នា គិតតាំងពីកើតឡើងទៅទល់នឹងពេលដែលវិនាសទៅវិញនោះ ច្រើនឆ្នាំណាស់នឹងរាប់ថាមួយកោដិឬមួយអសង្ខេយ្យឆ្នាំដូច្នេះមិនអស់ ព្រោះលោកធាតុឬចក្ក-វាឡនោះមានអាយុវែងណាស់ ទើបអ្នកប្រាជ្ញដើមខ្មែរទាំងឡាយ មានព្រះពុទ្ធជាដើម សន្មតហៅថាកប្ប គឺលោកធាតុឬចក្កវាឡនោះមានអាយុមួយកប្បទើបវិនាសទៅវិញ។

ក្នុងគម្ពីរសំយុត្តនិកាយ ត្រង់តិណកដ្ឋវគ្គ មានសេចក្តីតំណាលថាៈ សម័យមួយព្រះសម្ពុទ្ធទ្រង់គង់នៅទៀបក្រុងសាវត្ថី មានភិក្ខុមួយរូបចូលទៅគាល់ ហើយក្រាបទូលសួរថាៈ បពិត្រព្រះអង្គដ៏ចម្រើន កប្បមានកាលវែងប៉ុន្មាន?

ព្រះមានព្រះភាគទ្រង់ត្រាស់ថាៈ

ឌីឃោ ខោ ភិក្ខុ កប្បោ សោ ន សុករោ សង្ខាតុំ
ឯត្តកានិ វស្សានិ ឥតិ វា ឯត្តកានិ វស្សសតានិ ឥតិ
វា ឯត្តកានិ វស្សសហស្សានិ ឥតិ វា ឯត្តកានិ
វស្សសតសហស្សានិ ឥតិ វា។

ម្នាលភិក្ខុ កប្បមានកាលវែងណាស់ កប្បនោះមិនងាយនឹងរាប់ប៉ុណ្ណោះឆ្នាំក្តី

ប៉ុណ្ណោះរយឆ្នាំក្ដី ប៉ុណ្ណោះពាន់ឆ្នាំក្ដីឬថាប៉ុណ្ណោះសែនឆ្នាំបានឡើយ។

ភិក្ខុនោះទូលសួរទៀតថាៈ បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះអង្គអាចធ្វើពាក្យឧបមាបានឬទេ?

ព្រះមានព្រះភាគទ្រង់ត្រាស់ថាអាចធ្វើបាន ទើបទ្រង់សម្ដែងឧបមាថាៈ

សេយ្យថាបិ ភិក្ខុ មហាសេលោ បព្វតោ យោជនំ
អាយាមេន យោជនំ វិត្ថារេន យោជនំ ឧព្វេធេន
អច្ឆិទ្ទោ អសុសិរោ ឯកឃនោ តមេនំ បុរិសោ
វស្សសតស្ស វស្សសតស្ស អច្ចយេន កាសិកេន
វត្ថេន សកឹ សកឹ បរិមជ្ជេយ្យ ខិប្បតរំ ខោ សោ
ភិក្ខុ មហាសេលោ បព្វតោ ឥមិនា ឧបក្កមេន បរិក្ខយំ
បរិយាទានំ គច្ឆេយ្យ ន ត្វេវ កប្បោ ឯវំ ទីឃោ ខោ
ភិក្ខុ កប្បោ។

ម្នាលភិក្ខុ ឧបមាដូចជាភ្នំថ្មសុទ្ធដ៏ធំ មានបណ្ដោយមួយយោជន៍ ទទឹងមួយយោជន៍ កម្ពស់មួយយោជន៍ មិនបានធ្លុះ មិនមានប្រហោង ជាភ្នំតាន់ កន្លងមួយរយឆ្នាំៗទៅ មានបុរសយកសំពត់កាសិកៈមកបោសភ្នំនោះម្ដងៗ ម្នាលភិក្ខុ ភ្នំថ្មសុទ្ធដ៏ធំនោះគប្បីដល់នូវការអស់ទៅ រេចទៅដោយសេចក្ដីព្យាយាមនេះឆាប់ជាង ឯកប្បមិនទាន់អស់នៅឡើយ ម្នាលភិក្ខុ កប្បមានកាលវែងយ៉ាងនេះឯង។

ក្នុងកាលជាខាងក្រោយមក មានភិក្ខុមួយរូបចូលទៅគាល់ហើយក្រាបទូលសួរដូចមុនទៀត, ព្រះមានព្រះភាគទ្រង់ត្រាស់ថាៈ

សេយ្យថាមិ ភិក្ខុ អាយសំ នគរំ យោជនំ អាយាមេន

យោជនំ វិត្ថារេន យោជនំ ឧព្វេធេន បុណ្ណំ
សាសបានំ គុឡំ កាពន្ធំ តតោ បុរិសោ វស្សសតស្ស
វស្សសតស្ស អច្ចយេន ឯកមេកំ សាសបំ ឧទ្ធរេយ្យ
ខិប្បតរំ ខោ សោ ភិក្ខុ មហាសាសបរាសិ ឥមិនា
ឧបក្កមេន បរិក្ខយំ ចរិយាទានំ គច្ឆេយ្យ ន ត្វេវ
កប្បោ ឯវំ ទីឃោ ខោ ភិក្ខុ កប្បោ។

*ម្នាលភិក្ខុ ឧបមាដូចជានគរដែលព័ទ្ធដោយកំពែង មានបណ្តោយមួយយោជន៍ ទទឹងមួយយោជន៍ កម្ពស់មួយយោជន៍ពេញដោយគ្រាប់ស្ពៃ ជានគរគេបិទភ្ជាប់ដោយដុំដីស្អិត កន្លងមួយរយឆ្នាំៗទៅ មានបុរសទៅរើសយកគ្រាប់ស្ពៃដ៏ធំនោះ គប្បីដល់នូវការអស់ទៅរលីងទៅដោយសេចក្តីព្យាយាមនេះឆាប់ជាង ឯកប្បមិនទាន់អស់នៅឡើយ ម្នាលភិក្ខុកប្បមានកាលវែងយ៉ាងនេះឯង ។*

*កប្បនេះចែកចេញជាច្រើនយ៉ាងទៅទៀត ចែកជា២ក៏មាន ជា៣ក៏មាន ជា៤ក៏មានជា៦ក៏មាន។*

កប្បចែកជា២គឺ

*១– សំវដ្តកប្ប កប្បវិនាស*

*២– វិវដ្តកប្ប កប្បចំរើន។*

ចែកជា៣គឺ

*១– តេជោសំវដ្តៈ កប្បវិនាសដោយភ្លើង*

*២– អាបោសំវដ្តៈ កប្បវិនាសដោយទឹក*

*៣– វាយោសំវដ្តៈ កប្បវិនាសដោយខ្យល់។*

ចែកជា៤គឺ

១–អាយុកប្ប ខួបអាយុ គឺខួបអាយុក្ខ័យមនុស្ស

២–អន្តរាកប្ប កំណត់អាយុក្ខ័យចុះនិងខ័យឡើង គឺមនុស្សមានអាយុក្ខ័យចុះដល់១០ឆ្នាំស្លាប់ ហើយខ័យឡើងវិញដល់អាយុមួយអសំខេយ្យ, ការខ័យចុះទៅហើយខ័យឡើងមកវិញមួយលើកៗ ហៅថា អន្តរាកប្បមួយៗ។

៣–អសំខេយ្យកប្ប កំណត់យកអន្តរាកប្ប៦៤ដង ហៅថាអសំខេយ្យកប្បមួយ។

៤–មហាកប្ប កំណត់យកអសំខេយ្យកប្ប៤ដង ទើបហៅថាមហាកប្បមួយ។

ចែកជា៤ទៀតគឺ

១–សំវដ្តកប្ប គិតតាំងពីពេលដែលកប្បវិនាសទៅទល់នឹងវិនាសអស់រលីង។

២–សំវដ្តដ្ឋាយិកប្ប គិតតាំងពីពេលដែលកប្បវិនាសអស់រលីងទៅទល់នឹងពេលដែលកកើតឡើងទៀត។

៣–វិវដ្តកប្ប គិតតាំងពីពេលដែលកប្បកើតឡើងទៅទល់នឹងពេលដែលព្រះអាទិត្យ ព្រះចន្ទកើតមាន។

៤–វិវដ្តដ្ឋាយិកប្ប គិតតាំងពីពេលដែលព្រះអាទិត្យ ព្រះចន្ទកើតមានទៅទល់នឹងពេលដែលកប្បវិនាសទៅវិញ។

ចែកជា៦គឺ

១–សារកប្ប កប្បដែលមានព្រះពុទ្ធត្រាស់តែ១ព្រះអង្គ

២–មណ្ឌកប្ប កប្បដែលមានព្រះពុទ្ធត្រាស់២ព្រះអង្គ

៣–វរកប្ប កប្បដែលមានព្រះពុទ្ធត្រាស់៣ព្រះអង្គ

៤–សារមណ្ឌកប្ប កប្បដែលមានព្រះពុទ្ធត្រាស់៤ព្រះអង្គ

៥–ភទ្ទកប្ប កប្បដែលមានព្រះពុទ្ធត្រាស់៥ព្រះអង្គ

៦–សុញ្ញកប្ប កប្បដែលគ្មានព្រះពុទ្ធត្រាស់។

## អធិប្បាយអំពីកប្បវិនាសកប្បចំរើន

# កប្បវិនាស

កប្បដែលវិនាសទៅវិញដោយហេតុ៣យ៉ាងគឺៈ

១–វិនាសដោយភ្លើងឆេះកាល បើលោកធាតុឬចក្កវាឡទាំង១សែនកោដិមានអាយុគ្រប់មួយកប្បហើយ ត្រូវភ្លើងឆេះកម្ទេចលោកធាតុទាំងនោះ មុនដែលនឹងភ្លើងឆេះនោះ មានភ្លៀងធំធ្លាក់ចុះក្នុងលោកទាំង១សែនកោដិ មនុស្សទាំងឡាយនាំគ្នាត្រេកអរសោបព្រោះបណ្តុះពូជធញ្ញជាតិផ្សេងៗ កាលបើដុះល្មមគោស៊ីបានហើយ ភ្លៀងក៏រាំងលែងធ្លាក់ចុះមកទៀតអស់សែនឆ្នាំជាច្រើន។ សត្វដែលមានកម្មស្រាលៗ ក៏ស្លាប់មុនសត្វដែលមានកម្មអាក្រក់ បានទៅកើតក្នុងព្រហ្មលោកទាំងអស់។ លុះកាលកន្លងយូរទៅទឹកដែលដក់នៅក្នុងទីនោះៗរីងអស់ទៅ ពួកសត្វទាំងឡាយមានត្រីនឹងអណ្តើកជាដើមក៏ស្លាប់អស់ទៅ។ សត្វនរកក្តី[៣] តិរច្ឆានក្តី មនុស្សក្តី ស្លាប់ទៅបានទៅកើតក្នុងស្ថានសួគ៌ ខំចម្រើនឈានក្នុងស្ថានសួគ៌បានទៅកើតក្នុងព្រហ្មលោកទាំងអស់។ ត្បិតមុនដែលភ្លើងនឹងឆេះចំនួនជាមួយសែនឆ្នាំ មានទេវតាមួយអង្គឈ្មោះលោកព្យូហាចុះអំពីទេវលោកមក ក្លែងភេទជាមនុស្សស្លៀកសំពត់ក្រហមរំសាយសក់ មានមុខទទឹកជោគដោយទឹកភ្នែក ជូតទឹកភ្នែកហើយដើរទៅតាមផ្លូវមនុស្ស ប្រកាសប្រាប់ថាអ្នកទាំងឡាយនៅមួយសែនឆ្នាំទៀតកប្បនឹងវិនាស លោកនឹងវិនាស ទឹកសមុទ្រនឹងរីងខះ ផែនដីភ្នំសុមេរុ ទេវលោក ព្រហ្មលោកនឹងវិនាស អ្នកទាំងឡាយចូលចម្រើន

មេត្តាភាវនានិងខំបម្រើមាតាបិតាដោយគោរព។ ក្នុងពេលនោះមនុស្សទាំងឡាយជាសប្បុរសបានស្តាប់ពាក្យទេវតានោះហើយ ក៏កើតសវេគតក់ស្លុតមុនគេ ប្រញាប់ប្រញាល់ធ្វើបុណ្យទានបម្រើមាតាបិតាមិនមានសេចក្តីប្រមាទ លុះដល់ស្លាប់ទៅបានទៅកើតក្នុងទេវលោក ខំចម្រើនឈានក្នុងទេវលោក បានសម្រេចឈានក៏បានទៅកើតក្នុងព្រហ្ម-លោកទៅ មិនបានទៅរងទុក្ខវេទនាយូរដូចជាជនអសប្បុរសឡើយ។

## ក្នុងគម្ពីរវិសុទ្ធិមគ្គថ្រាប់ថា

វស្សូបច្ឆេទតោ បន ឧទ្ធំ ទីឃស្ស អទ្ធុនោ អច្ចយេន ទុតិយោ សុរិយោ បាតុភវតិ...ដូច្នេះជាដើម។

សេចក្តីថា: រាប់តាំងអំពីកាលដែលរាំងភ្លៀង កន្លងកាលមកជាយូរអង្វែង មានព្រះអាទិត្យទី២កើតឡើងប្រាកដ។ កាលព្រះអាទិត្យពីរមានក្នុងលោកហើយ យប់និងថ្ងៃមិនប្រាកដ។ ព្រះអាទិត្យមួយរះឡើង មួយលិចទៅ, ក្នុងលោកមានកម្តៅព្រះអាទិត្យជាប់ជានិច្ចរាល់វេលា។ ក្នុងកាលមុនអំពីកាលដែលព្រះអាទិត្យញុំាងកប្បឱ្យវិនាសនោះ សុរិយទេវបុត្រតែងមានក្នុងសុរិយវិមាន ដល់មកក្នុងពេលដែលព្រះអាទិត្យញុំាងកប្បឱ្យវិនាសនោះ សុរិយវិមាន មិនមានទេវបុត្រឡើយ។ សុរិយមណ្ឌលដែលកើតថ្មីមានកម្តៅក្លាហានណាស់ ពពកនឹងអ័ព្ទក្នុងអាកាសបាត់អស់ ជាអាកាសប្រាសចាកមន្ទិល។ កាលបើព្រះអាទិត្យ២កើតឡើងក្នុងលោក ហើយទឹកក្នុងស្ទឹងតូចៗរីងខះអស់ឥតសល់។ លុះកន្លងកាលយូរទៅព្រះអាទិត្យទី៣កើតឡើង ទឹកក្នុងស្ទឹងធំទាំង៥ក៏រីងខះអស់ទៀត។ លុះកាលកន្លងយូរទៅ ព្រះអាទិត្យទី៤កើតឡើង ទឹកក្នុងស្រះធំទាំង៧ មានស្រះអនោតត្តជាដើមក៏រីងខះអស់ទៀត។ លុះកាលកន្លងយូរទៅ ព្រះអាទិត្យទី៥កើតឡើង ទឹកក្នុងមហាសមុទ្រក៏រីងខះអស់ទៀត ក្នុងលោកទាំងមូលគ្មានទឹកមួយដំណក់ឡើយ។ លុះ

កន្លងកាលយូរទៅព្រះអាទិត្យទី៦កើតឡើង ចក្កវាឡទាំងមួយសែនកោដិមានផ្សែងហុយទ្រលោមឡើង មានដំរហូរអំពីផែនដី។ លុះកន្លងកាលយូរទៅ ព្រះអាទិត្រទី៧កើតឡើង ចក្កវាឡទាំងមួយសែនកោដិ មានអណ្តាតភ្លើងឆេះសន្ធោសន្ធៅ ឆេះរំលាយភ្នំកម្ពស់មួយយោជន៍ៗជាដើមដរាបដល់ភ្នំសិនេរុ បណ្តាលឲ្យវិនាសសាបសូន្យទៅ។ អណ្តាតភ្លើងដែលឆេះនោះក៏ហួចទៅឆេះស្ថានចាតុមហារា-ជិកា ឆេះស្ថានតាវត្តិង្ស ស្ថានយាមា ស្ថានតុសិត ស្ថាននិម្មានរតី ស្ថានបរនិម្មិតវសវតី និងឆេះនូវស្ថានព្រហ្មជាន់ខាងក្រោមទៅទល់ត្រឹមស្ថានអាភស្សរៈ។

សា យាវ អណុមត្តម្បិ សង្ខារគតំ អត្ថិ តាវ ន និព្វាយតិ។

អណ្តាតភ្លើងនោះ បើរបស់ដែលឆេះនោះមិនទាន់អស់ ក៏មិនទាន់រលត់ ឆេះដរាបដល់អស់មិនឱ្យសល់ផេះ ទើបរលត់ទៅ ឧបមាដូចជាភ្លើងឆេះប្រេង។ ទីខាងក្រោមជាអាកាសទទេ ខាងលើក៏ជាអាកាសទទេដូចគ្នាទាំងអស់មានងងឹតធំតែមួយ។

២– វិនាសដោយទឹក កាលបើលោកធាតុឬចក្កវាឡមានអាយុមួយកប្បហើយត្រូវវិនាសទៅវិញ។ ការដែលវិនាសដោយទឹកនោះមានទំនាក់ទំនងគ្នានឹងវិនាសដោយភ្លើងដែរ គ្រាន់តែប្លែកដូច្នេះ គឺមហាមេឃបណ្តាលភ្លៀងទឹកក្រុតឱ្យធ្លាប់ចុះមកក្នុងចក្កវាឡទាំងមួយសែនកោដិ សម្ភារៈទាំងឡាយមានភ្នំជាដើម កាលបើត្រូវទឹកក្រុតហើយក៏រលាយរលួយទៅអស់ ទឹកក្រុតនោះខ្យល់បក់ទ្រទ្រង់ជុំវិញ រំលាយនូវសម្ភារៈខាងក្រោមហើយ រំលាយនូវស្ថានសួគ៌៦ជាន់និងស្ថានព្រហ្មច្រើនជាន់ទៀតទៅទល់នឹងត្រឹមស្ថានព្រហ្មឈ្មោះ សុភកិណ្ហា។ ទឹកក្រុតក៏រីងខះអស់ទៅ សម្ភារៈទាំងឡាយមានភ្នំជាដើម ដែលរលាយដោយទឹកក្រុតនោះឧបមាដែលអំបិលបង់ទៅក្នុងទឹក រលាយអស់ឥតមានសល់អ្វីតិចតួចឡើយ។ ទីខាងក្រោមជាអាកាសទទេ ខាងលើក៏ជាអាកាស

ទទេដូចគ្នាទាំងអស់ មានឯងឹតធំតែមួយ។

៣–កប្បវិនាសដោយខ្យល់ កាលបើរលាយដោយធាតុឬចក្កវាឡមានអាយុមួយកប្បហើយ ត្រូវវិនាសទៅវិញ។ ការដែលវិនាសដោយខ្យល់នោះ មានទំនាក់ទំនងដូចគ្នានឹងវិនាសដោយភ្លើងដែរ គ្រាន់តែប្លែកគ្នាដូច្នេះគឺៈ មហាមេឃញ៉ាំងខ្យល់ព្យុះធំឱ្យកើតឡើងបក់បំបើុងធុលីល្អិតៗ ឱ្យហុយទៅឰដ៏អាកាសវិនាសបាត់អស់ទៅជាមុន ទើបបក់បំបើុងនូវដីខ្សាច់គ្រួសតូចធំនិងដុំថ្មដរាបដល់ដើមឈើនិងភ្នំឱ្យប៉ះទង្គិចគ្នាអណ្តែតទៅឰដ៏អាកាស វិនាសអស់ឥតសល់កម្ទេច ទើបបក់បំបែកផែនដីក្នុងមួយសែនចក្កវាឡនិងស្ថានសួគ៌៦ជាន់ ស្ថានព្រហ្ម ដរាបទៅទល់ស្ថានព្រហ្មឈ្មោះវេហប្ផលា ឱ្យល្អិតល្អន់ខ្ទេចខ្ទីអស់ឥតមានសល់ធុលីបន្តិចបន្តួចឡើយ។ ខ្យល់ក៏វិនាសបាត់អស់ទៅ ទីខាងក្រោមជាអាកាសទទេ ខាងលើក៏ជាអាកាសទទេដូចគ្នាទាំងអស់ មានឯងឹតធំតែមួយ។

កប្បដែលវិនាសទៅវិញដោយអាការៈបីយ៉ាង ដូចរៀបរាប់មកនេះឯង។ អាការៈទាំងបីយ៉ាងនេះមិនមែនវិនាសផ្លាស់ប្តូរគ្នាម្តងៗម្នាក់ទេ គឺវិនាសយ៉ាងនេះ។

វិនាសដោយភ្លើង៧ដង ត្រូវវិនាសដោយទឹកម្តង, វិនាសដោយភ្លើងនិងទឹកៗតែយ៉ាងនេះចំនួន៦៣ដង ទើបវិនាសដោយខ្យល់ម្តង។ នេះជាធម្មតានៃការវិនាសរបស់កប្ប ។

ក្នុងគម្ពីរវិសុទ្ធិមគ្គប្រាប់អំពីហេតុដែលបណ្តាលឱ្យវិនាសថា

អកុសលមូលេសុ ហិ ឧស្សន្នេសុ ឯវំ លោកោ វិនស្សតិ។ សោ ច ខោ រាគេ ឧស្សន្នតរេ អគ្គិនា វិនស្សតិ ទោសេ ឧស្សន្នតរេ ឧទកេន វិនស្សតិ។ កេចិ បន ទោសេ ឧស្សន្នតរេ អគ្គិនា រាគេ ឧស្សន្នតរេ

ឧទកេនាតិ វឌ្ឍន្តិ។ មោហោ ឧស្សន្នតរេ វាតេន វិនស្សតិ។

*សេចក្ដីថា: កាលបើអកុសលមូលទាំងឡាយគឺ: រាគៈ ទោសៈ មោហៈ ក្រាស់ឡើងហើយ លោកតែងវិនាសដោយការយ៉ាងនេះ។ លោកនោះឯង កាលបើមានរាគៈក្រាស់ជាង ត្រូវវិនាសដោយទឹក។ ចំណែកខាងកេចិតអាចារ្យនិយាយថា: កាលបើមានទោសៈក្រាស់ជាង ត្រូវវិនាសដោយភ្លើង, បើមានរាគៈក្រាស់ជាង ត្រូវវិនាសដោយទឹក ។ បើមានមោហៈក្រាស់ជាង ត្រូវវិនាសដោយខ្យល់។*

*ចប់កប្បវិនាសដោយសង្ខេប*

# កប្បចំរើន

*ធម្មតាសង្ខារលោក កាលបើកប្បមុនវិនាសអស់ហើយ សង្ខារលោកត្រូវសាងលោកជាថ្មីឡើងទៀត។ ការសាងលោកជាថ្មីនោះមុនដំបូងមហាមេឃបង្អុលនូវទឹកភ្លៀងឱ្យធ្លាប់ចុះមកបំពេញចក្កវាឡទាំងមួយសែនកោដិ មុនដំបូងមានដំណក់ទឹកតូចៗដូចជាទឹកសន្សើម យូរៗទៅគ្រាប់ភ្លៀងកាន់តែធំឡើងៗប៉ុនដើមឈូក, ប៉ុនឈើសូល, ប៉ុនអង្រែ, ប៉ុនដើមត្នោត ដរាបដល់មានគ្រាប់ប៉ុនៗភ្នំ។ ខ្យល់ក៏បក់ទឹកនោះឱ្យឃនខាប់, ទឹកនោះមានសណ្ឋានដូចជាទឹកដក់នៅលើស្លឹកឈូក ទើបហួតខះស្រកចុះទៅវិញជាលំដាប់។ វារៈដែលភ្លៀងនោះយូរណាស់ មិនចេះរាំងម្ដងឡើយ ចំនួនជាមួយកប្បទើបរាំង គំនរទឹកគរទៅទល់ត្រឹមស្ថានព្រហ្ម។ កាលបើខ្យល់ហួតទឹកនោះឱ្យខះស្រកចុះហើយ ស្រកដល់កន្លែងដែលជាស្ថានព្រហ្មពីពេលមុន ក៏កើតជាស្ថានព្រហ្មទៅ ស្រកដល់កន្លែងស្ថានសួគ៌៦ជាន់ ក៏កើតជាស្ថានសួគ៌ទៅ, ស្រកដល់កន្លែងកើតទ្វីប កើតកោះ កើតសមុទ្រ ក៏កើតជាភ្នំ ជាទ្វីប ជាកោះ ជាសមុទ្រទៅ។ សង្ខារលោកតាក់តែងក្នុងពេលមុនមានសភាពបែបណា សង្ខារលោកតាក់តែងក្រោយ ក៏មាន*

សភាពបែបនោះ ឥតមានខុសគ្នាឡើយ។

កាលបើទឹកស្រកចុះមកដល់ទីនឹងកើតទ្វីបហើយ ពពុះទឹកនោះមានរសផ្អែមកក កើតជាដី ដីដែលកើតឡើងនោះអណ្តែតលើទឹកឬដូចជាទឹកដោះក្តៅលាយអណ្តែត លើទឹក។ ផែនដីមានរសនោះ មានសម្បុរល្អ មានក្លិនក្រអូប មានរសផ្អែម មានសម្បុរ ដូចជាទឹកដោះថ្លា មានរសឆ្ងាញ់ពិសាដូចជាទឹកឃ្មុំដែលលាយដោយកូនឃ្មុំ ឬដូច បាយមធុបាយាសដែលមានទឹកតិច។ ការកើតផែនដីនោះ ទីពោធិបល្ល័ង្កកើតមុន មានគុម្ពឈូកមួយដើមដុះឡើងជាបុព្វនិម្មិត។ ក្នុងទីពោធិបល្ល័ង្កនោះ បើមានព្រះពុទ្ធ ១អង្គនឹងឧប្បត្តិឡើងក្នុងកប្បនោះ ឈូកមានផ្កាតែមួយ[៥] កប្បមានសភាពបែបនេះ ហៅថា "សារកប្ប"។ បើមានព្រះពុទ្ធ២អង្គនឹងឧប្បត្តិឡើងក្នុងកប្បនោះ ឈូកមានផ្កា ពីរ កប្បមានសភាពបែបនោះ ហៅថា "មណ្ឌកប្ប"។ បើមានព្រះពុទ្ធ៣អង្គនឹងឧប្បត្តិ ឡើងក្នុងកប្បនោះ ឈូកមានផ្កាបី កប្បមានសភាពបែបនេះ ហៅថា "វរកប្ប"។ បើ មានព្រះពុទ្ធ៤អង្គនឹងឧប្បត្តិឡើងក្នុងកប្បនោះ ឈូកមានផ្កាបួន កប្បមានសភាពបែប នេះ ហៅថា "សារមណ្ឌកប្ប"។ បើមានព្រះពុទ្ធ៥អង្គនឹងឧប្បត្តិឡើងក្នុងកប្បនោះ ឈូកមានផ្កាប្រាំ កប្បមានសភាពបែបនេះ ហៅថា "ភទ្ទកប្ប"។ បើមិនមានព្រះពុទ្ធ នឹងឧប្បត្តិឡើងក្នុងកប្បនោះទេ គ្មានដើមឈូកដុះជាបុព្វនិម្មិតឡើយ កប្បមានសភាព បែបនេះ ហៅថា "សុញ្ញកប្ប"។

ផ្កាឈូកនោះ១ក្តី ២ក្តី ៣ក្តី ៤ក្តី ៥ក្តី កើតឡើងជាប់គ្នាតែនឹងដើមមួយដូចជា ចង្កោមនៃផ្កាកណ្ណិកា។

គ្រានោះឯងសត្វចុះមកអំពីព្រហ្មលោកជាច្រើន មានសត្វខ្លះជាអ្នកល្មោភឡោភ ឃើញដីមានរសឆ្ងាញ់នោះ ក៏គិតថា យីអើនេះជាអ្វីអេះ! ក៏យកចង្អុលដៃត្តិះយកដី

មានរសនោះមកលិទ្ធមើល រសដីក៏ជ្រួតជ្រាបទៅសព្វសរសៃសម្រាប់ទទួលនូវរស សេចក្ដីប្រាថ្នាក្នុងរសក៏កើតមានឡើងដល់សត្វនោះ។ មានសត្វដទៃទៀតយកតម្រាប់តាម នាំគ្នាយកចង្អុលដៃត្តិះយកដីមានរសមកលិទ្ធភ្លក្សមើល រសដីក៏ជ្រួកជ្រាបទៅក្នុងសរីរកាយរបស់សត្វនោះៗ។ លំដាប់នោះ សត្វទាំងឡាយក៏នាំគ្នាកាយយកដីដែលមានរសមកពូតធ្វើជាពំនូតហើយបរិភោគ។ កាលបើសត្វទាំងនោះបរិភោគដីមានរសហើយ ពន្លឺដែលភ្លឺចេញអំពីកាយនៃសត្វទាំងនោះ ក៏សាបសូន្យបាត់ទៅ ងងឹតក៏កើតឡើង សត្វទាំងនោះឃើញងងឹតក៏ភ័យខ្លាចគ្រប់ៗគ្នា។

គ្រានោះសុរិយមណ្ឌល មានទទឹងនិងបណ្ដោយ៥០យោជន៍ ក៏កើតឡើងដើម្បីកម្ចាត់បង់នូវភ័យនៃសត្វទាំងនោះៗ ឃើញសុរិយមណ្ឌលហើយត្រេកអររីករាយនាំគ្នាហៅថា សុរិយៈៗ។ ព្រះអាទិត្យធ្វើពន្លឺក្នុងវេលាថ្ងៃហើយលិចបាត់ទៅ។ សត្វទាំងនោះកើតភ័យម្ដងទៀតនិយាយគ្នាថា យើងបានពន្លឺហើយ ពន្លឺនោះបាត់ទៅវិញ យើងបានពន្លឺអ្វីទៀតហ្ន៎!។

គ្រានោះ ចន្ទមណ្ឌលមានទទឹងនិងបណ្ដោយ៤៩យោជន៍ក៏កើតឡើង។ សត្វទាំងនោះបានឃើញចន្ទមណ្ឌលហើយ ត្រេកអររីករាយនាំគ្នាហៅថា ចន្ទៈៗដូច្នេះ។

កាលបើព្រះអាទិត្យព្រះចន្ទកើតប្រាកដហើយ ផ្កាយនក្ខត្តប្ញក្សក៏កើតឡើង វេលាថ្ងៃនិងយប់ក៏កើតឡើង, ១ខែនិងកន្លះខែក៏កើតឡើង, រដូវនិងឆ្នាំក៏កើតឡើង, ភ្នំព្រះសុមេរុ, ភ្នំហិមវន្ត, ភ្នំចក្កវាឡ, ទ្វីបទាំង៤និងសមុទ្រក៏កើតឡើងប្រាកដ ក្នុងថ្ងៃពេញបូណ៌មី ខែផល្គុណមិនមុនមិនក្រោយ ដូចមានប្រាប់បញ្ជាក់ក្នុងគម្ពីរវិសុទ្ធិមគ្គត្រង់អភិញ្ញានិទ្ទេសថាៈ តេ ច ខោ អបុព្វំ អចរិមំ ផគ្គុណបុណ្ណមីទិវសេ បាតុភវន្តិ ដូច្នេះ។

កាលសត្វទាំងនោះបរិភោគដីមានរស យកដីជាចំណីអាហារហើយស្ថិតនៅអស់កាលជាយូរអង្វែង, សេចក្តីរឹងប៉ឹងក្នុងរាងកាយរបស់សត្វទាំងនោះ ក៏កើតឡើង ព័ណ៌សម្បុរក៏ប្លែកៗគ្នាប្រាកដឡើង។ សត្វខ្លះមានសម្បុរល្អ ខ្លះមានសម្បុរអាក្រក់។ ពួកសត្វដែលមានសម្បុរល្អ មើលងាយពួកសត្វដែលមានសម្បុរអាក្រក់ថាៈ ពួកយើងមានសម្បុរល្អជាងសត្វពួកនុ៎ះ យើងគ្រាន់បើប្រសើរជាង, សត្វពួកនុ៎ះមានសម្បុរអាក្រក់អន់ជាងពួកយើងៗ មិនត្រូវរាប់រកគួរសមនឹងពួកសត្វនុះឡើយ។ កាលបើសត្វទាំងនោះមានសេចក្តីប្រកាន់ខ្លួននិងការមើលងាយគ្នាជាបច្ច័យហើយ ដីមានរសឆ្ងាញ់ពិសាក៏វិនាសសាបសូន្យអស់ទៅ។ លុះដីមានរសវិនាសអស់ហើយបប្បដកៈក្រមរផែនដីក៏កើតប្រាដកឡើង។ ក្រមរផែនដីនោះមានសណ្ឋានដូចជាផ្សិតក្បាលពស់ មានព័ណ៌ដូចសប្បិសុទ្ធឬដូចនវនីតសុទ្ធមានរសឆ្ងាញ់ពិសាដូចទឹកឃ្មុំ ដែលឥតលាយដោយកូនឃ្មុំ។

គ្រានោះឯង សត្វទាំងនោះនាំគ្នាបរិភោគក្រមរផែនដី យកក្រមរផែនដីជាចំណីអាហារ ស្ថិតនៅអស់កាលជាយូរអង្វែង។ កាលសត្វទាំងនោះ នាំគ្នាបរិភោគក្រមរផែនដី ការរឹងប៉ឹងក្នុងរាងកាយរបស់សត្វទាំងនោះ ក៏កើតឡើងក្រៃលែងលើសប្រមាណ ព័ណ៌សម្បុរក៏ប្លែកៗគ្នាប្រាកដឡើង។ ពួកសត្វទាំងនោះមានសេចក្តីប្រកាន់ខ្លួនមើលងាយគ្នាដូចមុនទៀត។ ក្រមរផែនដីក៏សាបសូន្យអស់ទៅ វល្លិឈ្មោះបទាលតា មានរសផ្អែមកើតឡើង វល្លិនោះប្រាកដដូចវល្លិត្រកួន មានសម្បុរល្អ មានក្លិនក្រអូប មានរសឆ្ងាញ់ មានសម្បុរដូចសប្បិសុទ្ធឬដូចនវនីតសុទ្ធ មានរសដូចកូនឃ្មុំលាយដោយទឹកឃ្មុំ។ សត្វទាំងឡាយនោះក៏នាំគ្នាបរិភោគ យកវល្លិបទាលតានោះជាចំណីអាហារស្ថិតនៅអស់កាលជាយូរអង្វែង។ កាលសត្វទាំងនោះបរិភោគវល្លិបទាលតា ការរឹង

ប៉ុងនៃសរីរៈក៏កើតប្រាកដឡើងលើសប្រមាណ ពណ៌សម្បុរក៏ប្លែកៗគ្នា។ ពួកសត្វទាំងនោះមានសេចក្តីប្រកាន់ខ្លួន មើលងាយគ្នាដូចមុនទៀត វល្លិបទាលតាក៏សាបសូន្យបាត់ទៅ។ ស្រូវសាលីធ្លិនឯង ជាស្រូវគ្មានកន្ទក់ គ្មានអង្កាម សស្អាត មានក្លិនក្រអូប មានផ្លែចេញមកជាចង្កោមកើតប្រាកដឡើង។ សត្វទាំងឡាយនាំគ្នាយកស្រូវសាលី ត្រង់ទីណាបរិភោគក្នុងវេលាព្រឹក ដល់វេលាល្ងាចស្រូវដុះឡើងត្រង់ទីនោះ នាំគ្នាមកបរិភោគទៀតឥតពិបាកដើរទៅរកទីដទៃទៀតឡើយ។ គ្រានោះ សត្វទាំងឡាយ ក៏បរិភោគស្រូវសាលីធ្លិនឯង យកស្រូវនោះជាចំណីអាហារ ស្ថិតនៅអស់កាលជាយូរអង្វែង។ កាលសត្វទាំងនោះនាំគ្នាបរិភោគស្រូវនោះហើយ ការរឹងប៉ឹងនៃសរីរកាយក៏កើតឡើងលើសប្រមាណ ទាំងពណ៌សម្បុរក៏ប្លែកៗគ្នាប្រាកដឡើង មុខដំបៅទាំងឡាយក៏បែកធ្លាយជាទ្វារតូចទ្វារធំ សម្រាប់បញ្ចេញនូវមូត្រលាមក ភេទប្រុស ភេទស្រីក៏កើតប្រាកដឡើង។ ពួកស្រីៗសម្លឹងមើលពួកប្រុសៗសម្លឹងមើលពួកស្ត្រីហួសវេលាតម្រេកក៏កើតឡើង សេចក្តីក្តៅក្រហាយព្រោះតម្រេកក៏ប្រជុំចុះក្នុងកាយ។ តាំងពីពេលនោះសត្វទាំងឡាយនាំគ្នាសេពមេថុនធម្ម ព្រោះមានរាគៈជាបច្ច័យ។ សម័យនោះពួកសត្វណាបានឃើញពួកសត្វដែលកំពុងសេពមេថុនធម្ម ក៏យកអាចម៍ដីបោះទៅខ្លះយកផេះបាចទៅ ខ្លះយកអាចម៍គោបោះទៅ ខ្លះក៏ជេរស្តីបន្ទោសដល់សត្វដែលកំពុងសេពមេថុនធម្មនោះ។ កាលបើសត្វទាំងនោះ ដល់នូវភាពជាអ្នកសេពមេថុនធម្មស៊ប់ហើយ ក៏នាំគ្នាផ្តើមធ្វើផ្ទះបិទបាំងការសេពអសទ្ធម្មតាំងពីពេលនោះមក។

ក្នុងកាលជាខាងក្រោយមក មានសត្វពួកខ្លះជាអ្នកខ្ជិលច្រអូសបានគិតយ៉ាងនេះថា៖ ឃើអើ! អាត្មាអញទៅយកស្រូវក្នុងវេលាព្រឹកបរិភោគបានតែក្នុងវេលាព្រឹក ទៅយកក្នុងវេលាល្ងាច បរិភោគបានតែក្នុងពេលល្ងាច ហៅពេញជាលំបាកអ្វីម្ល៉េះ!

ណ្ហើយចុះអញគួរតែទៅយកស្រូវក្នុងវេលាព្រឹក ហើយទុកបរិភោគក្នុងវេលាល្ងាចផងទើបស្រួល។ វេលានោះឯងមានសត្វមួយរូបចូលទៅរកសត្វនោះ និយាយបបួលថាៈ នែសត្វក៏ចម្រើនអ្នកចូលមក យើងនឹងទៅយកស្រូវសាលីមកធ្វើជាអាហារ។ សត្វនោះឆ្លើយថា ណ្ហើយកុំ យើងបានយកមកបរិភោគគ្រប់គ្រាន់ហើយ។ សត្វដែលទៅបបួលនោះ ឮដូច្នោះគិតឃើញថាស្រួល ក៏យកតម្រាប់តាមទៅយកស្រូវមកទុកបរិភោគបានចំនួនជាពីរថ្ងៃក៏មាន បីថ្ងៃក៏មាន បួនថ្ងៃក៏មាន ច្រើនថ្ងៃជាងនេះក៏មាន។

លុះសត្វទាំងនោះ នាំគ្នាផ្តើមបរិភោគស្រូវសាលីដែលខ្លួនបានយកមកទុកដូច្នោះហើយ កន្ទក់រុំព័ទ្ធអង្ករ អង្កាមរុំព័ទ្ធអង្ករ ក៏កើតមានឡើង សូម្បីកន្លែងដែលយកស្រូវនោះក៏លែងមានស្រូវដុះទៀត។

គ្រានោះឯង សត្វទាំងឡាយបានប្រជុំគ្នាហើយនិយាយត្អូញត្អែរថាៈ ម្នាលគ្នាយើងទាំងឡាយ ធម៌លាមកអាក្រក់កើតឡើងដល់យើងហើយ ធម៌លាមកអាក្រក់កើតប្រាកដដល់សត្វហើយ។ កាលពីដើមពួកយើងជាអ្នកកើតដោយឈានចិត្ត មានបីតិជាអាហារ មានពន្លឺភ្លឺចេញអំពីកាយត្រាច់ចរទៅតាមអាកាសបានដូចបំណង ឥឡូវសូម្បីតែស្រូវសាលីក៏មានកន្ទក់មានអង្កាម ទីដែលច្រូតហើយលែងដុះឡើងវិញ ព្រោះហេតុនៃធម៌លាមកកើតដល់យើងទាំងឡាយ បើដូច្នេះយើងគួរយើងចែកស្រូវសាលីគ្នា ចែកទីដីសម្រាប់ដាំស្រូវដល់គ្នានឹងគ្នា។ លំដាប់នោះឯងសត្វទាំងឡាយ ក៏នាំគ្នាចែកស្រូវសាលី បោះព្រំខ័ណ្ឌដោយខ្លួនៗ។ វេលានោះមានសត្វមួយរូបជាតិអ្នកលាមកអាក្រក់បានលាក់សំចៃចំណែកស្រូវរបស់ខ្លួនទុក លួចយកចំណែករបស់សត្វដទៃដែលគេមិនបានឱ្យមកបរិភោគ។ សត្វទាំងឡាយក៏ចាប់សត្វនោះ លុះចាប់បានហើយក៏ស្តីបន្ទោសថាៈ ឱ!សត្វអើយឯងធ្វើអំពើអាក្រក់ណាស់មិនគួរឯងលាក់សំចៃចំណែក

ខ្លួនទុក ហើយលួចយកចំណែករបស់សត្វដទៃមកបរិភោគសោះ ឯងកុំធ្វើយ៉ាងនេះទៀត។ វេលាខាងក្រោយមកសត្វនោះលួចទៀតអស់វារៈពីរបីដង សត្វទាំងឡាយក៏ចាប់បានសត្វនោះទៀត លុះចាប់បានហើយក៏ស្តីបន្ទោសជាច្រើន សត្វខ្លះទះតប់នឹងដៃ ខ្លះវាយនឹងដំបង។ ក្នុងពេលនោះការលួចក៏កើតប្រាកដឡើង, ការតិះដៀលក៏កើតប្រាកដឡើង, ការនិយាយកុហក, ការដាក់អាជ្ញាក៏កើតប្រាកដឡើងក្នុងលោក។

ក្នុងគម្ពីរទីឃនិកាយ ត្រង់អគ្គញ្ញសូត្របាប់ថាៈ កាលព្រះបរមគ្រូអរហន្តសម្មាសម្ពុទ្ធគង់ក្នុងវត្តបុព្វារាម បានសម្តែងប្រាប់ដល់សាមណេរពីររូបថាៈ

អថខោ តេ វាសេដ្ឋា សត្តា សន្និបតឹសុ សន្និបតិត្វា អនុត្ថុនឹសុ ចាបកា វត ភោ ធម្មា សត្តេសុ ចាតុភូតា យត្រ ហិ នាម អទិន្នាទានំ បញ្ញាយិស្សតិ គរហា បញ្ញាយិស្សតិ មុសាវាទោ បញ្ញាយិស្ស តិទណ្ឌាទានំ បញ្ញាយិស្សតិ យន្នូន មយំ ឯកំ សត្តំ សម្មន្នេយ្យាម យោ នោ សម្មាខីយិតព្វំ ខីយេយ្យ សម្មាគរហិតព្វំ គរហេយ្យ សម្មាបព្វាជេតព្វំ បព្វាជេយ្យ មយំ បនស្ស សាលីនំ ភាគំ អនុប្បទស្សាមាតិ អថខោ តេ វាសេដ្ឋា សត្តា...ដូច្នេះជាដើម ។

សេចក្តីថាៈ ម្នាលវាសេដ្ឋៈនិងភារទ្វាជៈ គ្រានោះឯងពួកសត្វទាំងនោះមកប្រជុំគ្នា លុះប្រជុំគ្នាហើយក៏ត្អូញត្អែរថាៈ យីអើហ្ន៎? ធម៌លាមកទាំងឡាយ កើតប្រាកដដល់សត្វទាំងឡាយហើយ ព្រោះថាការលួចទ្រព្យគេក៏កើតឡើង ការតិះដៀលក៏កើតប្រាកដឡើង ការនិយាយកុហកក៏កើតប្រាកដឡើង ការដាក់អាជ្ញាក៏កើតប្រាកដឡើង បើដូច្នេះគួរតែយើងសន្មតសត្វម្នាក់ ឱ្យជាអ្នកបន្ទោសសត្វដែលគួរបន្ទោសតាមហេតុ ឱ្យតិះដៀលសត្វដែលគួរតិះដៀលតាមហេតុ ឱ្យបណ្តេញសត្វដែលគួរបណ្តេញតាម

ហេតុ ឱ្យដល់ពួកយើង ចំណែកខាងពួកយើង ត្រូវជូនចំណែកស្រូវសាលីទាំងឡាយ ដល់សត្វនោះៗ ម្នាលវាសេដ្ឋនិងភារទ្វាជៈ ទើបសត្វនោះនាំគ្នាចូលទៅរកសត្វដែល អ្នកមានរូបល្អ គួររមិលមើល គួរជ្រះថ្លា មានស័ក្តិធំ គឺព្រះពោធិសត្វ។ លុះចូលទៅ ដល់ហើយបាននិយាយដូច្នេះថា បពិត្រសត្វដ៏ចម្រើន ចូលអ្នកបន្ទោសសត្វដែលគួរ បន្ទោសតាមហេតុ ចូរអ្នកតិះដៀលសត្វដែលគួរតិះដៀលតាមហេតុ ចូរអ្នកបណ្ដាញ សត្វដែលគួរបណ្ដេញតាមហេតុចុះ ពួកយើងនឹងជូនចំណែកស្រូវសាលីទាំងឡាយ ដល់អ្នក។

ព្រះពោធិសត្វ បានទទួលពាក្យរបស់សត្វទាំងនោះថា ស្រួលហើយ។ តាំងពី ពេលនោះមក ក៏បន្ទោសសត្វដែលគួរបន្ទោស តិះដៀលសត្វដែលគួរតិះដៀលឬ បណ្ដេញចេញតាមហេតុ។ ពួកសត្វទាំងនោះក៏បានជាចំណែកស្រូវសាលីដល់ព្រះ ពោធិសត្វគ្រប់ៗគ្នា។ មហាជនក៏សន្មតព្រះពោធិសត្វនោះថា “មហាសន្មត” ដូច្នេះ ដោយមានបទវិគ្រោះថា **មហាជនសម្មតោ’តិ>មហាសម្មតោ** (សត្វណា) ដែល មហាជនសន្មតហើយ (សត្វនោះ) ឈ្មោះថា មហាសម្មតៈ សត្វគឺមហាជនសន្មត ហើយ, ពាក្យថា មហាសន្មតៈ កើតមានតាំងពីពេលនោះមក។ ពួកសត្វខ្លះហៅ ពោធិសត្វនោះថា ខត្តិយៈ ដូច្នេះក៏មាន ព្រោះព្រះពោធិសត្វនោះជាអធិបតីនៃស្រែ ទាំងឡាយ ដោយមានបទវិគ្រោះថាៈ **ខេត្តានំ អធិបតី’តិ>ខត្តិយោ** (សត្វណា) ជា អធិបតីនៃស្រែទាំងឡាយ (សត្វនោះ) ឈ្មោះ ខត្តិយៈ, សត្វជាអធិបតីនៃស្រែទាំង ឡាយ ពាក្យថា ខត្តិយឬក្សត្រ មានតាំងពីពេលនោះមក។ ពួកសត្វខ្លះហៅព្រះ ពោធិសត្វថា រាជា ព្រោះព្រះពោធិសត្វនោះ ញុំាងសត្វទាំងឡាយឱ្យពេញចិត្តដោយ ធម៌ មានបទវិគ្រោះថា **ធម្មេន បរេសំ រញ្ជេតី’តិ>រាជា** (សត្វណា) ញុំាងសត្វ

ទាំងឡាយដទៃ ឱ្យពេញចិត្តដោយធម៌ (សត្វនោះ) ឈ្មោះថា រាជា សត្វអ្នកញ៉ាំងសត្វទាំងឡាយដទៃឱ្យពេញចិត្តដោយធម៌, ពាក្យថា រាជា មានតាំងពីពេលនោះមក។

រឿងនេះក៏សង្ខេបតែប៉ុណ្ណេះ, ចាប់តាំងពីពេលនោះមកលោកចេះតែមានសេចក្ដីចម្រើន ខ្ជាយឡើងជាច្រើនលើកច្រើនគ្រា, នឹងទាញយករឿងខ្ជាយចុះខ្ជាយឡើងនោះមកសម្ដែងតាមដែលមាននៅក្នុងគម្ពីរទីឃនិកាយ ត្រង់ចក្កវត្តិសូត្រដូចតទៅនេះ។

កាលព្រះសម្ពុទ្ធបរមគ្រូគង់នៅក្នុងព្រៃក្បែរមាតុលានគរ នាដែនមគធៈ។ សម័យនោះព្រះអង្គទ្រង់សម្ដែងប្រាប់ភិក្ខុទាំងឡាយថាៈ

**ភូតបុព្វំ ភិក្ខវេ រាជា ទឡ្ហនេមិ នាម អហោសិ ចក្កវត្តិ ធម្មិកោ ធម្មរាជា ចាតុរន្តោ វិជិតាវី ជនបទត្ថាវរិយប្បត្តោ សត្តរតនសមន្នាគតោ។ តស្សិមានិ សត្ត រតនានិ**...ដូច្នេះជាដើម។

សេចក្ដីថាៈ ម្នាលភិក្ខុទាំងឡាយ កាលពីព្រេងនាយមក មានព្រះរាជា១ព្រះអង្គ ព្រះនាមទល្ហនេមិ ជាស្ដេចចក្រពត្តិ ព្រះអង្គជាធម្មិកធម្មរាជ ជាឥស្សរៈលើដែនដីដែលមានសមុទ្រទាំង៤ជាទីបំផុត ជាស្ដេចឈ្នះសង្គ្រាម ទ្រង់មានជនបទដល់នូវសេចក្ដីមាំមួនស្ថាពរ ទ្រង់បរិបូណ៌ដោយរតន៧ប្រការ។ ព្រះបាទទល្ហនេមិនោះទ្រង់ត្រួតត្រាគ្រប់គ្រងដែនដី ដែលមានសាគរជាព្រំប្រទល់នេះដោយធម៌ដ៏ស្មើមិនបាច់ប្រើអាជ្ញាមិនបាច់ប្រើគ្រឿងសស្ត្រាវុធ។ លុះកាលកន្លងទៅជាច្រើនរយច្រើនពាន់ឆ្នាំ ទើបព្រះបាទទល្ហនេមិទ្រង់ត្រាស់នឹងបុរសម្នាក់ថា បើអ្នកឃើញចក្ករតន៍ច្យុតឃ្លាតចាកទីក្នុងកាលណា អ្នកត្រូវប្រាប់ដល់យើងក្នុងកាលនោះ។ លុះកាលកន្លងទៅជាច្រើនពាន់ឆ្នាំ បុរសនោះបានឃើញចក្ករតន៍ឃ្លាតចាកទីក៏ចូលទៅទូលដល់ព្រះបាទទល្ហនេមិ។

គ្រានោះ ព្រះបាទទល្ហនេមិទ្រង់ហៅព្រះរាជកុមារជាបុត្រច្បងមក ហើយទ្រង់

ត្រាស់ដូច្នេះថា ម្នាលកុមារមាសឪពុក ឮថាចក្ករតន៍ទិព្វរបស់យើងច្យុតឃ្លាតចាកទីហើយ, សេចក្តីនេះឪពុកធ្លាប់ឮថា បើចក្ករតន៍ទិព្វរបស់ស្តេចចក្រពត្តិអង្គណាច្យុតចាកទីហើយ តពីនោះមក ស្តេចអង្គនោះមិនរស់នៅបានយូរឡើយ ឯកាមរបស់មនុស្សឪពុកបានបរិភោគឆ្អែតស្កប់ស្កល់ហើយ។ សម័យនេះជាសម័យដែលឪពុកគួររកកាមជាទិព្វវិញ, ម្នាលកុមារមាសឪពុក ចូរអ្នកគ្រប់គ្រងផែនដី ដែលមានសមុទ្រជាព្រំប្រទល់នេះចុះ ឯឪពុកនឹងកោរសក់ពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាវៈ ចេញចាកផ្ទះចូលកាន់ផ្នួស។ លំដាប់នោះឯងព្រះបាទទឡ្ហនេមិទ្រង់ល្អងលោមព្រះរាជបុត្រច្បង ឱ្យគ្រោកអរក្នុងរាជសម្បត្តិដោយប្រពៃហើយ ក៏ទ្រង់ចេញចាករាជាគារស្ថាន ចូលទៅបួសជាឥសី។

កាលបើព្រះរាជឥសីទើបនឹងទ្រង់ព្រះផ្នួសបាន៧ថ្ងៃ ចក្ករតន៍ទិព្វក៏បាត់ទៅ។ លំដាប់នោះ មានបុរសម្នាក់ចូលទៅគាល់ព្រះរាជបុត្រដែលទើបនឹងបានមុទ្ធាភិសេកជាក្សត្រថ្មីនោះបានក្រាបទូលថា បពិត្រព្រះសម្មតិទេព សូមទ្រង់ជ្រាប ត្បិតចក្ករតន៍ទិព្វបាត់ទៅហើយ។ ព្រះរាជាទ្រង់ព្រះសណ្តាប់ហើយទ្រង់តូចព្រះរាជហឫទ័យ សោយនូវសេចក្តីមិនសប្បាយ ទើបស្តេចចូលទៅគាល់ព្រះរាជឥសីជាបិតា ក្រាបទូលថាៈ បពិត្រព្រះសម្មតិទេព សូមទ្រង់ជ្រាប ត្បិតចក្ករតន៍ទិព្វបាត់ទៅហើយ។ ព្រះរាជឥសីទ្រង់ត្រាស់នឹងព្រះរាជបុត្រថា ម្នាលបាកាលបើចក្ករតន៍បាត់ទៅហើយអ្នកកុំតូចចិត្ត កុំអន់ចិត្តឡើយ អ្នកចូលប្រព្រឹត្តចក្កពត្តិវត្ត (វត្តរបស់ស្តេចចក្រ) ដ៏ប្រសើរចុះ, បើអ្នកបានប្រព្រឹត្តល្អហ្មត់ចត់ហើយចក្ករតន៍ទិព្វមានកាំមួយពាន់ បរិបូណ៌ដោយអាការសព្វគ្រប់នឹងកើតប្រាកដដល់បាដែលកក់កេសាហើយរក្សាឧបោសថសីល ស្ថិតនៅលើប្រាសាទក្នុងថ្ងៃ១៥ ជាថ្ងៃឧបោសថនោះឯង។ ក្សត្រជាព្រះរាជបុត្រក៏ទូលសួរចក្កពត្តិ

វត្តនឹងព្រះរាជឥសីជាបិតា១ ប្រាប់ថាៈ ម្នាលបាបើដូច្នោះ អ្នកចូរអាស្រ័យនូវធម៌តែម្យ៉ាង ហើយធ្វើសក្ការៈចំពោះធម៌, គោរពធម៌, រាប់អានធម៌, បូជាធម៌, កោតក្រែងធម៌, យកធម៌ជាទង់ជ័យ, យកធម៌ជាស្ពាន, យកធម៌ជាអធិបតី, ចាត់ចែងនូវការរក្សាទប់ទល់ប្រកបដោយធម៌ ចំពោះជនខាងក្នុងគឺបុត្រភរិយា, ចំពោះពួកពល, ពួកក្សត្រ, ពួកជនចុះចូល, ពួកព្រាហ្មណ៍គហបតី, ពួកអ្នកនិគម, ពួកអ្នកជនបទ, ពួកសមណព្រាហ្មណ៍និងពួកម្រឹគបក្សី។ ម្នាលបាអ្នកកុំធ្វើអកុសលធម៌ក្នុងដែនរបស់អ្នកឡើយ បើជនណាក្នុងដែនរបស់អ្នកមិនមានទ្រព្យ អ្នកគប្បីផ្តល់ទ្រព្យដល់ជននោះ។ បើសមណព្រាហ្មណ៍ណាមួយក្នុងដែនរបស់អ្នកជាអ្នកមិនប្រមាទ តាំងនៅក្នុងខន្តីនិងសោរច្ចៈ អ្នកគប្បីចូលទៅរកសមណព្រាហ្មណ៍នោះសព្វៗកាល ហើយសាកសួរពីអំពើដែលប្រកបដោយទោសនិងមិនប្រកបដោយទោស អំពើជាកុសលនិងអកុសល, បើអ្នកបានស្តាប់ពាក្យរបស់សមណព្រាហ្មណ៍នោះហើយ អ្នកគប្បីវៀរនូវអំពើជាអកុសល ហើយសមាទាននូវអំពើជាកុសល, ម្នាលបានេះឯងជាវត្តដ៏ប្រសើររបស់ស្តេចចក្រ។

ក្សត្រជាព្រះរាជបុត្រ បានស្តាប់ឱវាទរបស់រាជឥសីជាបិតាហើយ ក៏ខំប្រព្រឹត្តចក្កពត្តិវត្តដ៏ប្រសើរនោះ បានកក់ព្រះកេសា សមាទានឧបោសថ ទ្រង់ស្ថិតក្នុងជាន់ប្រាសាទខាងលើ នាថ្ងៃ១៥ដែលជាថ្ងៃឧបោសថ។ ពេលនោះចក្ករតន៍ទិព្វមានកាំមួយពាន់ក៏កើតឡើង ទ្រង់ទតឃើញហើយ មានព្រះតម្រិះថាៈ ចក្ករតន៍ទិព្វកើតដល់ស្តេចអង្គណា ស្តេចអង្គនោះជាស្តេចចក្រ ឱហ្ន៎! អាត្មាអញជាស្តេចចក្រហើយតើ!។

គ្រានោះព្រះរាជាទ្រង់ក្រោកចាកអាសនៈ ធ្វើសំពត់ឧត្តរាសង្គៈ ឆៀងស្មាម្ខាងព្រះហស្តឆ្វេងកាន់កុណ្ឌីមាស ព្រះហស្តស្តាំប្រស់ព្រំចក្ករតន៍ ហើយអធិដ្ឋានថា សូម

ឲ្យចក្ករតន៍ដ៏ចម្រើនប្រព្រឹត្តទៅ សូមឱ្យចក្ករតន៍ដ៏ចម្រើនមានជ័យជម្នះចុះ។ គ្រានោះ ចក្ករតន៍ក៏អណ្តែតត្រសែតទៅកាន់ទិសខាងកើត ស្តេចចក្រពត្តិក៏អណ្តែតទៅតាមចក្ក-រតន៍នោះព្រមដោយចតុរង្គសេនា។ បើចក្ករតន៍ទៅប្រតិស្ឋាននៅប្រទេសណា ស្តេចក៏ចូលទៅតាំងព្រះរាជនិវេសន៍ក្នុងប្រទេសនោះ។ ឯស្តេចជាសឹកសត្រូវទាំងឡាយដែលស្ថិតនៅក្នុងទិសខាងកើត ក៏ចូលទៅគាល់ព្រះបាទចក្រពត្តិ ហើយក្រាបបង្គំទូលថា បពិត្រមហារាជទឹកដីរបស់ខ្ញុំព្រះអង្គជាទឹកដីរបស់ព្រះអង្គ សូមព្រះអង្គប្រៀនប្រដៅចុះ។ ព្រះបាទចក្រពត្តិមានព្រះបន្ទូលថា អ្នកទាំងឡាយមិនត្រូវសម្លាប់សត្វ, មិនត្រូវលួចទ្រព្យគេ, មិនត្រូវផឹកទឹកស្រវឹងឡើយ ចូរបរិភោគតែរបស់ដែលបរិភោគ។ លំដាប់នោះ ចក្ករតន៍ក៏អណ្តែតឆ្លងសមុទ្រទៅកាន់ទិសដទៃទៀតដរាបដល់គ្រប់ទិសទាំង៤ ព្រះបាទចក្រពត្តិក៏អណ្តែតទៅតាមមានទំនងដូចមុនទាំងអស់ ទ្រង់បង្ក្រាបសត្រូវលើដែនដីមានសមុទ្រជាព្រំប្រទល់ឱ្យស្ថិតនៅក្នុងសីល៥អស់ហើយ ទ្រង់ត្រឡប់ទៅកាន់ព្រះរាជធានីវិញ ចក្ករតន៍ក៏អណ្តែតទៅស្ថិតនៅក្នុងរបៀងនៃសាលាវិនិច្ឆ័យទៀបទ្វារព្រះបរមរាជវាំង ស្ថិតនៅនឹងថ្កល់ហាក់ដូចជាបាក់ភ្ជាប់ភ្លឺព្រះបរមរាជវាំងឱ្យភ្លឺព្រោងព្រាត។ ស្តេចចក្រពត្តិអង្គនេះដល់ចាស់ព្រះអង្គទៅ បានប្រគល់រាជសម្បត្តិដល់ព្រះរាជបុត្រច្បង តាមដំណើរប្រវេណីរបស់ព្រះរាជបិតា, ក្សត្រក្រោយៗមកចេះតែប្រតិបត្តិយ៉ាងនេះដរាបអស់៦តំណាស្តេច, ដល់មកស្តេចទី៧ មិនបានប្រតិបត្តិតាមប្រវេណីនោះឡើយ ចក្ករតន៍ក៏មិនកើតឡើងដល់ស្តេចអង្គនោះ ទើបទ្រង់ប្រៀនប្រដៅប្រជាជនតាមយោបលរបស់ព្រះអង្គ ទឹកដីប្រជាជនក៏មិនបានសុខចម្រើនដូចកាលស្តេចមុនៗឡើយ។

គ្រានោះឯង ពួកអាមាត្យ, មហាមាត្យ, ពួកហោរា, ពួកហ្មដំរី, ពួកអ្នករក្សាទ្វារ

និងពួកអ្នកចិញ្ចឹមជីវិតដោយមន្ត ក៏ប្រជុំគ្នាចូលទៅក្រាបទូលព្រះរាជាថាៈ បពិត្រព្រះសម្មតិទេព ពួកអ្នកជនបទមិនចម្រើនស្មើនឹងព្រះរាជាជាន់ដើមដែលប្រព្រឹត្តចក្កពត្តិវត្តដ៏ប្រសើរនោះឡើយ, បពិត្រព្រះសម្មតិទេព ពួកខ្ញុំព្រះអង្គសុទ្ធតែចេះចាំនូវចក្កពត្តិវត្ត សូមព្រះអង្គសួរខ្ញុំព្រះអង្គចុះ ខ្ញុំព្រះអង្គនឹងព្យាករថ្វាយ។ កាលនោះព្រះរាជាទ្រង់សួរនូវចក្កពត្តិវត្តនឹងពួកជនទាំងនោះៗ ក៏បានព្យាករថ្វាយ។ ព្រះរាជាកាលបើបានសវនាការព្យាករណ៍របស់ពួកជននោះហើយ ក៏ទ្រង់ចាត់ចែងនូវការរក្សាទប់ទល់គ្រប់គ្រងប្រកបដោយធម៌វិញ តែទ្រង់មិនបានព្រះរាជទានទ្រព្យដល់ពួកអ្នកខ្សត់ទ្រព្យឡើយ។ កាលបើដូច្នោះហើយសេចក្តីទ័លក្រក៏មានច្រើនឡើង។ កាលបើសេចក្តីទ័លក្រកើតមានច្រើនហើយ មានបុរសម្នាក់កាន់យកទ្រព្យរបស់ជនដទៃដែលហៅថាលួច, ពួករាជបុត្រចាប់បុរសនោះបាន នាំយកទៅថ្វាយស្តេច ហើយទូលតាមដំណើររឿង។ ព្រះរាជាត្រាស់សួរបុរសនោះថា អ្នកឯងលួចទ្រព្យគេមែនឬ?, ក្រាបទូលព្រះអង្គលួចគេមែន, ហេតុអីបានជាលួច?, បានជាទូលព្រះបង្គំលួចព្រោះមិនមានរបស់នឹងចិញ្ចឹមជីវិត។ លំដាប់នោះព្រះរាជាទ្រង់ព្រះរាជទានទ្រព្យដល់បុរសនោះ ហើយទ្រង់ត្រាស់បង្គាប់ថា អ្នកចូលយកទ្រព្យនេះទៅចិញ្ចឹមជីវិតខ្លួនផង ចិញ្ចឹមមាតាបិតាបុត្រភរិយាផង ចូរធ្វើទក្ខិណាទានចំពោះសមណព្រាហ្មណ៍ទាំងឡាយផង។ បុរសនោះក៏ទទួលប្រតិបត្តិតាមព្រះរាជឱង្ការ។ កាលជាខាងក្រោយមក ពួកមនុស្សទាំងឡាយបានឮថា ព្រះរាជាទ្រង់ព្រះរាជទានទ្រព្យដល់មនុស្សដែលលួចទ្រព្យគេដូច្នោះ ក៏នាំគ្នាលួចទ្រព្យរបស់ជនដទៃកាន់តែច្រើនឡើងៗ។ (អកុសលកម្មបថក៏ចាប់កំណើតកើតឡើងទៀតក្នុងលោកតាំងពីកាលនោះមក)។ លំដាប់នោះបុរសលួចទ្រព្យគេ ពួករាជបុរសចាប់បាននាំយកទៅថ្វាយស្តេច។ ព្រះរាជាទ្រង់ត្រាស់សួរបុរសនោះៗ ក៏ក្រាប

ទូលតាមដំណើរដូចបុរសអ្នកលួចមុនៗ។ វេលានោះព្រះរាជាទ្រង់ត្រិះរិះថាៈ បើអាត្មាអញនៅតែឱ្យទ្រព្យដល់អ្នកលួចទៀត អំណឹះតទៅមុខអទិន្នាទាននឹងរីងរឹតតែចម្រើនឡើងក្នុងលោក បើដូច្នោះអាត្មាអញផ្ចាញ់ផ្ចាលកាត់ក្បាលពួកអ្នកលួចចេញ។ ព្រះរាជាក៏ត្រាស់បង្គាប់រាជបុរសថាៈ នែ! ប្រស្ដែង អ្នកទាំងឡាយចូរចងស្លាបសេកបុរសនោះឱ្យជាប់ ហើយកោរក្បាលឱ្យរលីងទូងស្គរនាំបណ្ដើរសព្វច្រកល្ហក រួចនាំចេញទៅតាមទ្វារនគរខាងត្បូង ហើយកាត់ក្បាលវាចេញ។ រាជបុរសបានធ្វើតាមព្រះរាជអាជ្ញា, មនុស្សទាំងឡាយបានឮដំណឹងថា ព្រះរាជាទ្រង់បង្គាប់ឱ្យកាត់ក្បាលជនអ្នកលួចទ្រព្យដូច្នោះ ក៏នាំគ្នាធ្វើគ្រឿងសស្ត្រាវុធដ៏មុតក្លា ហើយនាំគ្នាប្លន់កាប់សម្លាប់អ្នកស្រុកខ្លះ អ្នកនិគមខ្លះ អ្នកនគរខ្លះ អ្នកដើរផ្លូវខ្លះ អូសយករបស់ជនទាំងឡាយនោះ ហើយកាប់សម្លាប់ទៀត បាណាតិបាតក៏កើតឡើងក្នុងលោកនាវេលានោះ។

កាលបើព្រះរាជាមិនព្រះរាជទានទ្រព្យដល់ជនអ្នកគ្មានទ្រព្យហើយ អទិន្នាទានក៏មានច្រើនឡើង, បាណាតិបាតក៏មានច្រើនឡើង។ តមកមានបុរសម្នាក់លួចទ្រព្យជនដទៃ រាជបុរសចាប់បាននាំមកថ្វាយព្រះរាជាៗត្រាស់សួរបុរសនោះៗ មិនហ៊ានឆ្លើយតាមពិតខ្លាចក្រែងព្រះរាជាសម្លាប់ ក៏ធ្វើជាកុហកថាមិនបានលួចទេ, មុសាវាទក៏កើតមានឡើង។ កាលបើមុសាវាទកើតមានឡើង ពរ៤ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ របស់សត្វក៏ថយចុះមក, មនុស្សដែលមានអាយុ១សែនឆ្នាំថយនៅត្រឹមតែ៨ហ្មឺនឆ្នាំ។ លុះកន្លងកាលយូរទៅក៏ថយចុះនៅត្រឹមតែ៤ហ្មឺនឆ្នាំនោះ ថយចុះនៅត្រឹមតែ២ហ្មឺនឆ្នាំ។ ពួកមនុស្សដែលមានអាយុ២ហ្មឺនឆ្នាំនោះ មានបុរសម្នាក់លួចទ្រព្យគេ មានបុរសម្នាក់ទៀតស្អប់បុរសនោះ ទៅទូលញុះញង់ព្រះរាជាឱ្យចាប់បុរសដែលលួចនោះ, បិសុណាវាចាក៏កើតមានឡើង។ កូនរបស់បុរសដែលមានអាយុ២ហ្មឺនឆ្នាំនោះ ក៏ថយ

ចុះនៅត្រឹមតែអាយុ១ហ្មឺនឆ្នាំ។ ពួកមនុស្សដែលមានអាយុ១ហ្មឺនឆ្នាំនោះខ្លះមានពណ៌សម្បុរល្អ ខ្លះអាក្រក់ ពួកអ្នកមានពណ៌សម្បុរអាក្រក់ស្រឡាញ់ពួកអ្នកមានពណ៌សម្បុរល្អ ក៏ប្រព្រឹត្តធ្វើមិច្ឆាចារក្នុងបុត្រភរិយារបស់ជនអ្នកដទៃ, កាមេសុមិច្ឆាចារក៏កើតមានឡើង។ កូនរបស់ជនអ្នកមានអាយុ១ហ្មឺនឆ្នាំនោះក៏ថយចុះនៅត្រឹមតែអាយុ៥ពាន់ឆ្នាំវិញ។ ក្នុងពេលដែលពួកមនុស្សមានអាយុ៥ពាន់ឆ្នាំនោះ ធម៌២ប្រការគឺៈ ផរុសវាចា និងសម្ផប្បលាបៈកើតមានឡើង។ កូនរបស់ជនអ្នកមានអាយុ៥ពាន់ឆ្នាំនោះក៏ថយចុះនៅត្រឹមតែអាយុ២ពាន់ឆ្នាំវិញ ធម៌មួយទៀត គឺមិច្ឆាទិដ្ឋិក៏កើតមានឡើងក្នុងពួកមនុស្សជំនាន់នោះ។

## បញ្ជាក់សេចក្តី

អកុសលកម្មបថទាំង១០ដែលកើតមានឡើងក្នុងលោក មិនមែនកើតរៀងគ្នាដូចខាងផ្នែកកុសលកម្មបថទេ កើតយ៉ាងនេះគឺៈ

| | |
|---|---|
| ១–អទិន្នាទាន | ៦–ផរុសវាចា |
| ២–បាណាតិបាត | ៧–សម្ផប្បលាបៈ |
| ៣–មុសាវាទ | ៨–អភិជ្ឈា |
| ៤–បិសុណាវាចា | ៩–ព្យាបាទ |
| ៥–កាមេសុមិច្ឆាចារ | ១០–មិច្ឆាទិដ្ឋិ |

## ខាងកុសលកើតយ៉ាងនេះ

| | |
|---|---|
| ១–វៀរចាកបាណាតិបាត | ៦–វៀរចាកផរុសវាចា |
| ២–វៀរអទិន្នាទាន | ៧–វៀរសម្ផប្បលាបៈ |
| ៣–វៀរកាមេសុមិច្ឆាចារ | ៨–វៀរអភិជ្ឈា |

៤–វៀរចាកមុសាវាទ ៩–វៀរចាកព្យាបាទ

៥–វៀរបិសុណាវាចា ១០–វៀរមិច្ឆាទិដ្ឋិ។

កាលបើអកុសលកម្មបថទាំង១០កើតច្រើនក្នុងលោកហើយ, កូនរបស់ជនអ្នកមានអាយុ១ពាន់ឆ្នាំនោះ ក៏ថយចុះនៅតែអាយុ៥រយឆ្នាំ។ ក្នុងពេលនោះធម៌អាក្រក់៣យ៉ាងកើតឡើងទៀតគឺៈ

**១–អធម្មរាគៈ** ត្រេកត្រអាលខុសគន្លងធម៌ គឺមនុស្សមានតម្រេកក្នុងមាតាបិតា, ម្តាយធំឪពុកធំ, ម្តាយមីង ឪពុកមានិងបងប្អូនបង្កើតរបស់ខ្លួន ។

**២–វិសមលោភៈ** ចង់បានហួសប្រមាណ ចង់បានឥតរបបគឺៈ របស់ដែលមិនគួរខ្លួនបានក៏ចង់បានដែរ នៅស្រុកឯណោះចង់បានរបស់ស្រុកឯណោះ នៅនគរឯណោះចង់បាននគរឯណោះ...។

**៣–មិច្ឆាធម្មៈ** ប្រាថ្នាខុសគន្លងធម៌ បានដល់តម្រេករបស់បុរសក្នុងបុរស តម្រេករបស់ស្ត្រីក្នុងស្ត្រី ។

កាលបើធម៌ទាំង៣នេះចម្រើនឡើងហើយ កូនរបស់ជនអ្នកមានអាយុ៥រយឆ្នាំក៏ថយចុះនៅតែអាយុ២៥០ឆ្នាំ។ ពេលនោះមនុស្សមិនសូវចេះគោរពមាតាបិតា គ្រូអាចារ្យ ចាស់ព្រឹទ្ធាចារ្យឡើយ អាយុក៏ចេះតែថយចុះមកនៅត្រឹម១០០ឆ្នាំ, ក្នុងរយៈកាលអាយុ១០០ឆ្នាំនេះ ព្រះសម្ពុទ្ធបរមគ្រូរបស់យើងទ្រង់ស្តេចចុះចាកស្ថានតុសិត មកចាប់បដិសន្ធិក្នុងផ្ទៃនៃនាងសិរីមហាមាយាជាអយិអគ្គទេពី របស់ព្រះបាទសិរីសុទ្ធោទនៈនាក្រុងកបិលព័ស្តុ ទ្រង់ចេញបព្វជ្ជាបានត្រាស់ជាព្រះពុទ្ធ, ព្រះអង្គទ្រង់បរិនិព្វានក្នុងព្រះជន្មគម្រប់៨០ឆ្នាំ, បានប្រតិស្ឋានព្រះពុទ្ធសាសនាទុក៥ពាន់ឆ្នាំតមកទៀត។ ឥឡូវនេះព្រះពុទ្ធសាសនាគន្លងទៅអស់២៥៤៩ឆ្នាំហើយ អាយុរបស់មនុស្សសព្វថ្ងៃនេះ

ថយចុះនៅតែជាង៧៤ទេ, ព្រោះមានក្បួនឱ្យគិតថា បើឆ្នាំកន្លងទៅ១០០ឆ្នាំអាយុក្ស័យរបស់មនុស្សថយអស់១ឆ្នាំ ។

ការថយចុះអាយុរបស់មនុស្សសព្វថ្ងៃនេះមិនទាន់ដល់ទេ នៅមានខ័យទៅរៀនដរាបដល់មនុស្សមានអាយុត្រឹមតែ១០ឆ្នាំ, ដូចមានព្រះពុទ្ធដីកាសម្តែង មាននៅក្នុងគម្ពីរទីឃនិកាយថាៈ

**ភវិស្សតិ ភិក្ខវេ សោ សមយោ យំ ឥមេសំ មនុស្សានំ ទសវស្សាយុកា បុត្តា ភវិស្សតិ**...ដូច្នោះជាដើម។

សេចក្តីថាៈ ម្នាលភិក្ខុទាំងឡាយ តទៅខាងមុខ នឹងមានសម័យដែលកូនរបស់មនុស្សទាំងនេះមានអាយុ១០ឆ្នាំ កាលបើមនុស្សមានអាយុ១០ឆ្នាំ ពួកនាងកុមារិកាមានអាយុ៥ឆ្នាំនឹងល្មមឱ្យមានប្តី ម្នាលភិក្ខុទាំងឡាយកាលបើមនុស្សមានអាយុ១០ឆ្នាំ រសដ៏ប្រសើរ គឺទឹកឃ្មុំ ទឹកដោះខាប់ ប្រេង ទឹកអំពៅ អំបិល នឹងបាត់អស់ទៅ មនុស្សទាំងឡាយស៊ីតែស្មៅគែលលក យកស្មៅគែលលកជាអាហារ, កុសលកម្មបថទាំង១០សាបសូន្យអស់ទៅ អកុសលកម្មបថចម្រើនឡើង។ ជនអ្នកគោរពមាតាបិតាជាដើមបាត់អស់ទៅ មនុស្សក្នុងលោកក្លាហានមិនស្គាល់ខុសត្រូវដូចសត្វតិរច្ឆាន នឹងកើតអន្តរជានមួយយ៉ាងធំក្នុងរយៈកាលនោះឯង ហៅថាកើតសត្ថន្តរកប្ប មនុស្សទាំងអស់ក្នុងលោកត្រូវវិនាសដោយគ្រឿងសស្ត្រាវុធ។ ក្នុងពេលដែលកើតសត្ថន្តរកប្បនោះ មនុស្សមានគ្រឿងសស្ត្រាវុធគ្រប់ដៃ ឃើញមនុស្សដូចគ្នា ដូចព្រានព្រៃឃើញម្រឹគ គឺមាតាបិតាឃើញកូនៗឃើញមាតាបិតា កើតសេចក្តីក្រោធខឹងស្អប់ដេញកាប់គ្នា ក្នុងរវាង៧ថ្ងៃកន្លងទៅ មានមនុស្សខ្លះដែលរត់រួចទៅពួនក្នុងព្រៃស្បាតជាដើម នាំគ្នាចេញមកវិញដើរស្កាត់រកគ្នា ក្នុងស្រុកជនបទមួយៗមានពីរបីនាក់ លុះជួបគ្នាហើយក៏

ឱបគ្នាទៅវិញទៅមកនិយាយរាក់ទាក់រកគ្នា មានចិត្តស្រឡាញ់គ្នាដូចបងប្អូនបង្កើត។

ការកើតសត្ថន្តរកប្បនេះ បើគិតពីត្រឹម ព.ស.២៤៩៥ នេះទៅនៅតែជាង ៦.៥០០ឆ្នាំទៀតទេដល់ហើយ (សូមគិតដេញមើលតាមដែលកន្លងទៅ១០០ឆ្នាំថយអស់១ឆ្នាំ)។

ឯមនុស្សដែលសល់នៅទាំងប៉ុន្មាន កាលបើបានជួបគ្នាហើយក៏ជំនុំគ្នាថាៈ ពួកមនុស្សដែលវិនាសសូន្យក្នុងលោកយ៉ាងនេះ មកតែអំពីការប្រព្រឹត្តិអកុសលធម៌ បើដូច្នោះមានតែពួកយើងនាំគ្នាប្រព្រឹត្តកុសលធម៌វិញ តើគួរប្រព្រឹត្តដូចម្ដេច? ណ្ហើយចុះពួកយើងគួរវៀរចាកបាណាតិបាត ព្រោះសត្វទាំងអស់ក្នុងលោកសុទ្ធតែចង់រស់គ្រប់គ្នា បើយើងសម្លាប់គេ យើងត្រូវតែស្លាប់ដូចគេវិញមិនខាន។ លុះគិតដូច្នោះហើយក៏នាំគ្នាតមមិនសម្លាប់សត្វទាំងពួង, កុសលកម្មបទទី១ ក៏កើតមានឡើងក្នុងលោកនាវេលានោះឡើងវិញ[៥]។ កូនរបស់មនុស្សអ្នកមានអាយុ១០ឆ្នាំនោះក៏មានអាយុឡើងដល់២០ឆ្នាំទើបស្លាប់។ លុះកន្លងកាលយូរទៅ ពួកមនុស្សទាំងនោះមានសេចក្ដីត្រិះរិះថា ពួកយើងដែលចម្រើនអាយុឡើងវិញព្រោះតែរក្សានូវកុសលធម៌ បើដូច្នេះយើងនាំគ្នារក្សានូវកុសលធម៌នោះឱ្យច្រើនក្រៃលែងឡើងទៀត។ ពួកមនុស្សទាំងនោះបាននាំគ្នារក្សាកុសលកម្មបថម្ដងមួយៗដរាបដល់គ្រប់ទាំង១០ អាយុក៏ចេះតែចម្រើនឡើងជាទ្វេភាគដរាបដល់មនុស្សមានអាយុ៨ហ្មឺនឆ្នាំ[៦]។ ពួកមនុស្សដែលមានអាយុ៨ហ្មឺនឆ្នាំនោះ នាងកុមារិកាមានអាយុ៥រយឆ្នាំទើបល្មមឱ្យមានស្វាមី។ អាពាធរបស់មនុស្សក្នុងជំនាន់នោះមានតែ៣គឺ ចំណង់ក្នុងអាហារ១, បរិភោគអាហារមិនបាន១, សេចក្ដីគ្រាំគ្រានៃរាងកាយ១។ កាលមនុស្សមានអាយុ៨ហ្មឺនឆ្នាំនោះជម្ពូទ្វីបនេះ ជាទ្វីបស្តុកស្តម្ភធំទូលាយមានស្រុក និគម រាជធានីតៗ គ្នាមួយរយៈមាន់ហើរធ្លាក់ ពេញ

ទៅដោយមនុស្សរកចន្លោះគ្មាន ដូចជាអវិចីនរក ពុំនោះសោតដូចជាព្រៃបបុសឬព្រៃរាំងភ្នំ។ ក្រុងពារាណសីសព្វថ្ងៃនេះ ប្រែឈ្មោះជាកេតុមតីរាជធានីទៅវិញ។ ក្នុងជម្ពូទ្វីបនេះមាននគរចំនួន៨ហ្មឺន៤ពាន់ មាននគរកេតុមតីជាប្រធាន មានមហារាជមួយព្រះអង្គព្រះនាម សង្ខៈ កើតក្នុងនគរកេតុមតីនោះឯង ជាស្តេចចក្រពត្តិ ជាឥស្សរៈលើផែនដីដែលមានសមុទ្រទាំង៤ជាព្រំប្រទល់ ទ្រង់មានជនបទស្ថិតស្ថេរបរិបូណ៌ដោយកែវ៧ប្រការ។ លុះកាលកន្លងយូរទៅ ព្រះមានព្រះភាគទ្រង់នាមមេត្តេយ្យៈទ្រង់ឧប្បត្តិឡើងក្នុងលោក, ឧប្បត្តិកើតក្នុងត្រកូលព្រាហ្មណ៍ដែលធំក្នុងនគរកេតុមតីនោះឯង, មាតារបស់ព្រះអង្គព្រះនាមព្រហ្មវតី បិតាព្រះនាមសុព្រហ្មា។ សម័យនោះមនុស្សលោកបរិបូណ៌ដោយសុខភាពគ្រប់យ៉ាងហាក់បីដូចជានៅក្នុងស្ថានសួគ៌។ ព្រះសម្ពុទ្ធព្រះនាមមេត្តេយ្យៈ នោះមានព្រះជន្មវែងចំនួន៨ហ្មឺនឆ្នាំទើបបរិនិព្វាន។

កាលដែលព្រះសម្ពុទ្ធព្រះនាម មេត្តេយ្យៈ បរិនិព្វានហើយ កន្លងកាលយូរបន្តិចទៅទៀត ភទ្ទកប្បផែនដីយើងនេះដល់កំណើតអាយុហើយត្រូវភ្លើងឆេះរំលោយឱ្យវិនាសក្នុងសម័យនោះឯង។ ព្រោះហេតុនោះសូមពុទ្ធមាមកជនទាំងឡាយខំបំពេញកុសលធម៌គ្រប់ៗគ្នាកុំខាន។

ចប់កប្បកថាដោយសង្ខេប

ព្រះបាឡាត់ឧត្តមលិខិត សុង-ស៊ីវ

សិទ្ធត្ថោ

គ្រូបង្រៀនបាលីនៅវត្តលង្កា

ក្រុងភ្នំពេញ

# លេខយោង

១–ពាក្យថា ចក្កវាឡ គឺលោកធាតុ ទីទ្រទ្រង់លោក បានជាហៅថា ចក្កវាឡ ព្រោះមានភ្នំព័ទ្ធជុំវិញដូចជាកង់រទេះ។

២–មួយយោជន៍ប្រវែង៤គាវុត ១គាវុតប្រវែង៨០ឧសភ, ១ឧសភប្រវែង២៥ ព្យាម; គិតទៅ១យោជន៍ប្រវែង៨ពាន់ព្យាម។

៣–សត្វនរកស្លាប់ក្នុងពេលដែលព្រះអាទិត្យទី៧កើតឡើង។

៤–ន័យខ្លះថា ក្នុងផ្កាឈូកនោះមានគ្រឿងបរិក្ខារទាំង៨, កាលផ្កាឈូកនោះកើតឡើង មហាព្រហ្មចុះមកកាច់យកទៅទុកនៅព្រហ្មលោក ដល់ព្រះពុទ្ធចេញបព្វជ្ជាយកមកថ្វាយ?។

៥–ន័យខ្លះថា នៅវេលាដែលសត្វទាំងនោះបានរក្សាកុសលកម្មបថទី១ហើយ មានភ្លៀងធ្លាក់ចុះមកជាខ្លាំង នាំសាកសពទម្លាក់ទៅក្នុងទន្លេសមុទ្រ ហើយមានផ្កាទិព្វធ្លាក់ចុះជាច្រើន។

៦–ន័យខ្លះថាឡើងដល់អាយុ១អសង្ខេយ្យឆ្នាំ ទើបថយមកវិញ។

ស្រាវជ្រាវដោយៈ ថាច់ សុតឹម